នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| ឯកសារបកប្រែ |
|---|
| TRANSLATION/TRADUCTION |
| ថ្ងៃ ខែ ឆ្នាំ (Date): 02-Nov-2011, 15:57 |
| CMS/CFO: Uch Arun |

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: [សាធារណៈ]

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សម្ងាត់/Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ: សាធារណៈ / Public

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ: 31/01/2012

ឈ្មោះមន្ត្រីដែលបានពិនិត្យ: Peang Tola

ហត្ថលេខា:

## ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ

| អ្នកដាក់ឯកសារ: | អ្នកទទួលឯកសារ: | ចម្លងជូន: |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះតុលាការកំពូល: | ជនជាប់ចោទ: |
| លោកស្រី ជា លាង | ចៅក្រម គង់ ស្រីម, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Motoo NOGUCHI | អៀង សារី |
| | ចៅក្រម សោម សិរីវឌ្ឍ | អៀង ធីរិទ្ធ |
| | ចៅក្រម A. KLONOWIECKA- MILART | ខៀវ សំផន |
| | ចៅក្រម ម៉ុង មុន្នីចរិយា | |
| | ចៅក្រម C. N. JAYASINGHE | មេធាវីការពារក្តីជនជាប់ចោទ: |
| | ចៅក្រម យ៉ា ណារិន | លោក សុន អរុណ |
| | សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី: | លោក Michiel PESTMAN |
| | | លោក Victor Koppe |
| | ពេជ អង្គ | លោក អាង ឧត្តម |

Elisabeth SIMONNEAU FORT

លោក Michael G.KARNAVAS
លោក ផាត់ ពៅសៀង
កញ្ញា Diana ELLIS QC
លោក ស សូវាន
លោក Jacques VERGÈS

# មាតិការឿង

**I. សេចក្តីផ្តើម និងប្រវត្តិនៃនីតិវិធី**....................................................................៤

**II. ឧទ្ធរណ៍**.......................................... ..........................................................៥

១. បណ្តឹងសាទុក្ខមិនអាចទទួលយកបានលើផ្នែកខ្លះ....................................................៥

*i. ទទ្ធីករណ៍ទីមួយសំរាប់ការប្តឹងសាទុក្ខគ្មានមូលដ្ឋានខាងអង្គហេតុនៅក្នុងសេចក្តីសំរេចដែលកំពុងតវ៉ាឡើយ*..........................................................................................៩

ii. *ទទ្ធីករណ៍ទីបីសំរាប់ការប្តឹងសាទុក្ខគ្មានមូលដ្ឋានខាងអង្គហេតុនៅក្នុងសេចក្តីសំរេចដែលកំពុងតវ៉ាឡើយ*..........................................................................................១១

*iii. ទទ្ធីករណ៍ទីបីនៃការប្តឹងសាទុក្ខមានចេតនាចង់ធ្វើជាតំណាងខុសជួសឲ្យការវែកញែកហេតុផលរបស់អង្គជំនុំជម្រះសាលាដំបូង*............................១២

២. បណ្តឹងសាទុក្ខខកខានក្នុងការបំពេញទៅតាមបទដ្ឋានស្តីពីការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ...........................................................................................................១៣

i. *បទដ្ឋានស្តីពីការពិនិត្យឡើងវិញតម្រូវឲ្យដើមបណ្តឹងសាទុក្ខបង្ហាញថាការចោទប្រកាន់ណាមួយអំពីកំហុសខាងអង្គច្បាប់ធ្វើឲ្យមោឃៈដល់សេចក្តីសំរេចដែលកំពុងតវ៉ា*.............១៣

ii. អង្គ *ជំនុំជម្រះសាលាដំបូងមិនមានកំហុសខាងអង្គច្បាប់ដូចធ្វើឲ្យមោឃៈដល់សេចក្តីសំរេចដែលកំពុងតវ៉ានោះឡើយ*...........................................................................១៦

iii. *បទដ្ឋាននៃការពិនិត្យឡើងវិញតម្រូវឲ្យដើមបណ្តឹងសាទុក្ខធ្វើការបង្ហាញឲ្យឃើញថាកំហុសដែលបានលើកឡើងចោទប្រកាន់នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិ គឺមិនសមហេតុសមផលផង និងមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែតផងដែលបណ្តាលឲ្យមានការខូចខាតដល់សិទ្ធិរបស់ដើមបណ្តឹងសាទុក្ខ*..........................................................................២៣

iv. *អង្គជំនុំជម្រះសាលាដំបូងមិនបានមានកំហុសដែលអាចឲ្យយល់ដឹងបានក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដែលបណ្តាលឲ្យមានការខូចខាតដល់សិទ្ធិរបស់ដើមបណ្តឹងសាទុក្ខនោះទេ*..................................................................................................២៥

៣. បណ្តឹងសាទុក្ខពឹងផ្អែកលើអង្គហេតុនានាដែលអង្គជំនុំជម្រះសាលាដំបូងមិនអាចមានបាន.......២៧

៤. ដំណោះស្រាយស៊ើបសួរដែលបានស្នើសុំ គឺហួសផុតពីវិសាលភាពនៃវិធាន ៣៥..................២៨

៥. យ៉ាងណាក៏ដោយ អង្គជំនុំជម្រះអាចចាត់ការ *តាមឆន្ទៈរបស់ខ្លួនផ្ទាល់* ដើម្បី ស៊ើបអង្កេតពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ នៅក្នុងសំណុំរឿង ០០២......................២៨

**III. សេចក្តីសន្និដ្ឋាន**...........................................................................................៣០

## I. សេចក្តីផ្តើម និងប្រវត្តិនៃនីតិវិធី

១- កាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញ*សេចក្តីសម្រេចរបស់ខ្លួនលើញត្តិស្នើសុំរបស់ នួន ជា ដែលទាក់ទងនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារលេខ E51/3, E82, E88, និងE92)* ("សេចក្តីសម្រេចដែលកំពុងតវ៉ា")[1]។ ការសម្រេចបញ្ចប់លើសារណាមួយឈុតពីក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា ("មេធាវីការពារក្តី") អង្គជំនុំជម្រះសាលាដំបូងបានបដិសេធលើសំណើសុំបំពេញកិច្ចស៊ើបសួរមួយដែលទាក់ទងនឹងការចោទប្រកាន់ពីការជ្រៀតជ្រែកចូលក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការក្រោមវិធាន៣៥នៃវិធានផ្ទៃក្នុង("វិធាន")[2]។ អង្គជំនុំជម្រះសាលាដំបូងក៏បានអនុញ្ញាតផងដែរលើផ្នែកខ្លះនៃសំណើសុំលើកទីពីរក្រោមវិធាន៣៥ ហើយបន្ទាប់ពីការស៊ើបសួរ បានកំណត់សម្រេចថាមិនមានការតម្រូវឲ្យមានវិធានការជាបន្ថែមទៀតទេ[3]។

២- កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ មេធាវីការពារក្តី បានដាក់នូវ*បណ្តឹងសាទុក្ខភ្លាមៗមួយរបស់ខ្លួនប្រឆាំងនឹងសេចក្តីសម្រេចស្តីពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ*("បណ្តឹងឧទ្ធរណ៍") តែជាភាសាអង់គ្លេសប៉ុណ្ណោះ[4]។

៣- កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ អង្គជំនុំជម្រះតុលាការកំពូល ("អង្គជំនុំជម្រះ") បានអនុញ្ញាតលើផ្នែកខ្លះនៃសំណើសុំបន្ថែមពេលវេលាកំណត់របស់សហព្រះរាជអាជ្ញា[5] ដើម្បីអនុញ្ញាតឲ្យដាក់ចម្លើយតបនេះ នៅក្នុងពេល១៥ថ្ងៃយ៉ាងយូរគិតតាមប្រក្រតីទិន ដែលត្រូវចាប់ផ្តើមថ្ងៃទីមួយបន្ទាប់ពីការដាក់បណ្តឹងឧទ្ធរណ៍ជាភាសាខ្មែរ[6]។ អត្ថបទច្បាប់ជាភាសាខ្មែរនៃបណ្តឹងសាទុក្ខត្រូវបានដាក់បញ្ចូលនៅក្នុង

---

[1] ឯកសារលេខ **E116** សេចក្តីសម្រេចលើញត្តិស្នើសុំរបស់ នួន ជា ទាក់ទងអំពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ចុះថ្ងៃទី៩ កញ្ញា ២០១១។

[2] ឯកសារលេខ **E82** សំណើសុំកិច្ចស៊ើបសួរអនុលោមតាមវិធាន៣៥នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី២៨ មេសា ២០១១ ("សំណើសុំលើកទីមួយ")

[3] ឯកសារលេខ **E92** សំណើសុំកិច្ចស៊ើបសួរលើកទី២ អនុលោមតាមវិធាន៣៥នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី៣ មិថុនា ២០១១ ("សំណើសុំលើកទីពីរ")។

[4] ឯកសារលេខ **E116/1/1** បណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ចុះថ្ងៃទី១០ តុលា ២០១១ ("បណ្តឹងសាទុក្ខរបស់ នួន ជា"), ដែលបានជូនដំណឹងដល់ភាគីនានា កាលពីថ្ងៃទី១១ តុលា២០១១។

[5] ឯកសារលេខ **E116/1/2** សំណើសុំពន្យារពេលកំណត់ក្នុងការឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា អនុលោមតាមវិធាន ១០៤(៤)(ឃ)នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី១៣ តុលា ២០១១។

[6] ឯកសារលេខ **E116/1/2/1** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ដែលសុំពន្យារពេលកំណត់សម្រាប់បង្កើការឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា អនុលោមតាមវិធាន ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី១៨ តុលា ២០១១។

សំណុំរឿងកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១រួចហើយ។ ហេតុនេះចម្លើយតបបច្ចុប្បន្នរបស់សហព្រះរាជអាជ្ញាត្រូវផុតកំណត់ដាក់នៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១១ ហើយដែលគោរពអនុវត្តទៅតាមពេលវេលាកំណត់ដែលបានឲ្យពន្យារពេល។

៤- សហព្រះរាជអាជ្ញាសូមលើកឡើងថា ទឡ្ហីករណ៍ទាំងបួននៃការប្ដឹងសាទុក្ខដែលបានដាក់ជូនដោយ នួន ជា នោះ គឺមិនអាចឲ្យទទួលយកបានលើផ្នែកខ្លះ ហើយលើសពីនេះ គឺមិនមានមូលដ្ឋានអ្វីដែលមានសារៈសំខាន់នោះទេ។ ជាបន្ថែមពីលើនេះ ការស្នើសុំសំណងជួសជុលដែលបានធ្វើឡើងនោះគឺវាមិនស្ថិតក្នុងវង្វង់សមត្ថកិច្ចរបស់អង្គជំនុំជម្រះនេះទេ។ ដែលអាស្រ័យហេតុនេះ បណ្ដឹងសាទុក្ខនេះមិនបានបំពេញគ្រប់តាមបទដ្ឋាននៃការពិនិត្យឡើងវិញជាធរមាននោះឡើយ ដែលគួរតែត្រូវបានបដិសេធចោល ទោះជាយ៉ាងណាក្ដី សហព្រះរាជអាជ្ញាចាត់ទុកថា ភ័ស្តុតាងស្ដីពីការជ្រៀតជ្រែកចូលនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការ គួរតែត្រូវបានពិនិត្យពិចារណា*តាមឆន្ទៈរបស់ខ្លួនផ្ទាល់ proprio motu* ដោយអង្គជំនុំជម្រះ ដើម្បីនឹងកំណត់សម្រេចអំពីថា តើការស៊ើបសួរណាមួយក្រោមវិធាន៣៥នៃវិធានផ្ទៃក្នុងត្រូវបានអនុញ្ញាតឲ្យដែរ ឬទេ នៅក្នុងកាលៈទេសៈនេះ។ សហព្រះរាជអាជ្ញាសូមលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះគួរតែត្រូវមានសមត្ថកិច្ច ដើម្បីដឹកនាំធ្វើកិច្ចស៊ើបសួរមួយអនុលោមតាមវិធាន៣៥នៅពេលដែលសំណុំរឿងលេខ០០២ កំពុងតែស្ថិតនៅក្នុងការរង់ចាំ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

## II. ទឡ្ហីករណ៍

### ១. បណ្ដឹងសាទុក្ខមិនអាចទទួលយកបានលើផ្នែកខ្លះ

៥- សព្រះរាជអាជ្ញាសូមលើកឡើងថា បណ្ដឹងសាទុក្ខនេះមិនអាចទទួលយកបានលើផ្នែកៗខ្លះ ដោយសារតែទឡ្ហីករណ៍ពីរក្នុងចំណោមបួននៃបណ្ដឹងសាទុក្ខដែលបានដាក់មកនោះ៖(១) គ្មានមូលដ្ឋានខាងអង្គហេតុដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការវែកញែកហេតុផលនោះឡើយ ឬ (២) មានចេតនាចង់ឲ្យអង្គជំនុំជម្រះសាលាដំបូងមានការយល់ខុសក្នុងការវែកញែកហេតុផល។ ហេតុដូចនេះទឡ្ហីករណ៍នៃការប្ដឹងសាទុក្ខទាំងនេះមិនអាចត្រូវបានចាត់ទុកដោយត្រឹមត្រូវបានថា បំពេញបានគ្រប់តាមលក្ខខណ្ឌតម្រូវតាមទម្រង់ការស្ដីពីភាពជាក់លាក់ដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងឡើយ។

៦- វិសាលភាពនៃបណ្តឹងសាទុក្ខមានការកម្រិតកំណត់យ៉ាងច្បាស់ សម្រាប់ការសម្រេចបញ្ចប់របស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំលើកទី១តែប៉ុណ្ណោះគត់[7]។ ហេតុនេះការសម្រេចបញ្ចប់របស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំលើកទីពីរ គឺស្ថិតនៅក្រៅវិសាលភាពនៃបណ្តឹងសាទុក្ខ។ វិធានផ្ទៃក្នុងបានចែងកំណត់ថា អង្គជំនុំជម្រះអាចពិនិត្យបានតែលើបញ្ហាណាដែលត្រូវបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខតែប៉ុណ្ណោះ[8]។

៧- បណ្តឹងសាទុក្ខ*ភ្លាមៗ* អាចបើកឱ្យធ្វើបានតែចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចំនួនបួនប្រភេទជាក់លាក់ប្រភេទតែប៉ុណ្ណោះគឺ៖ (១)សេចក្តីសម្រេចដែលមានអានុភាពធ្វើឱ្យបញ្ចប់ដល់ដំណើរការនីតិវិធី (២)សេចក្តីសម្រេចស្តីពីការឃុំខ្លួន និងការធានានៅក្រៅឃុំអនុលោមតាមវិធាន ៨២ (៣)សេចក្តីសម្រេចលើវិធានការការពារក្រោមវិធាន២៩.៤(គ)នៃវិធានផ្ទៃក្នុង និង(៤)សេចក្តីសម្រេចលើការជ្រៀតជ្រែកចូលក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការ ក្រោមវិធាន៣៥.៦នៃវិធានផ្ទៃក្នុង[9]។ រាល់សេចក្តីសម្រេចផ្សេងពីនេះរបស់អង្គជំនុំជម្រះសាលាដំបូង"អាចប្តឹងសាទុក្ខបានតែនៅក្នុងពេលជាមួយគ្នានឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើអង្គសេចក្តីប៉ុណ្ណោះ"[10]។ បណ្តឹងសាទុក្ខភ្លាមៗក៏ "មិនធ្វើឱ្យផ្អាកដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង"ផងដែរ[11]។ សហព្រះរាជអាជ្ញាចាត់ទុកថា សេចក្តីសម្រេចដែលកំពុងតវ៉ានេះបានរួមបញ្ចូលទាំងសេចក្តីសម្រេចមួយក្រោមវិធាន៣៥.៦នៃវិធានផ្ទៃក្នុងផង ដែលសេចក្តីសម្រេចនេះអាចបើកឱ្យធ្វើបណ្តឹងសាទុក្ខភ្លាមៗ"បាន[12]។

៨- សហព្រះរាជអាជ្ញាសង្កេតឃើញថា បណ្តឹងសាទុក្ខភ្លាមៗដែលបានបញ្ជូនមកមានលើកទឡ្ហីករណ៍ចំនួនបួននៃការប្តឹងសាទុក្ខ ដែលក្នុងនោះមាន ទឡ្ហីករណ៍បីដែលមានការកំហុសខាងអង្គច្បាប់ និង

---

[7] ឯកសារលេខ **E116/1/1** បណ្តឹងសាទុក្ខ កំណត់សម្គាល់លេខ៤*ខាងដើម* ត្រង់កថាខណ្ឌទី១ ("...ត្រឹមកម្រិតដែលវា បានសម្រេចបញ្ចប់នូវ ...")។

[8] វិធាន១១០ (១)នៃវិធានផ្ទៃក្នុង។

[9] វិធាន១១០ (៤) នៃវិធានផ្ទៃក្នុង។

[10] វិធាន១១០ (៤) នៃវិធានផ្ទៃក្នុង។

[11] វិធាន១១០ (៤) នៃវិធានផ្ទៃក្នុង។

[12] ឯកសារលេខ **E116** សេចក្តីសម្រេចដែលកំពុងតវ៉ា, កំណត់សម្គាល់លេខ១*ខាងដើម* ត្រង់កថាខណ្ឌទី២១ -២៣ និងផ្នែកដែលសម្រេចដោះស្រាយបញ្ចប់បាន ត្រង់ទំព័រ១០។

ទង្វើករណ៍មួយទៀតដែលមានកំហុសដែលអាចឲ្យយល់ដឹងបានអំពីការអនុវត្តន៍ឆន្ទានុសិទ្ធិ។ ចំពោះកំហុសខាងអង្គច្បាប់ក្នុងបណ្ដឹងសាទុក្ខបានចោទថា សេចក្ដីសម្រេចដែលកំពុងតវ៉ានេះ៖ (១) មិនបានផ្ដល់ការបញ្ជាក់មូលហេតុថា តើហេតុអ្វីបានជាមិនមានលើកឡើងពីការពោលអះអាងនានារបស់មេធាវីដែលទាក់ទងនឹងសំណុំរឿងលេខ០០២ ("ទង្វើករណ៍ទីមួយ")[13] (២)ការពោលអះអាងអំពីវិធានការដែលមិនត្រឹមត្រូវក្រោមវិធាន៣៥នៃវិធានផ្ទៃក្នុង ដែលភ្ជាប់គ្នាទៅនឹងបញ្ហានានាខាងអង្គហេតុដែលបច្ចុប្បន្ននេះកំពុងតែស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ហើយថែមទាំងអះអាងបន្ថែមទៀតអំពីអំពីការខូចខាតជាក់ស្ដែងចំពោះជនជាប់ចោទ ឬអំពីផលប៉ះពាល់ជារូបីយទៅលើដំណើរការនីតិវិធីដែលបច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូងត្រូវបានប្ដឹងមក("ទង្វើករណ៍ទីពីរ")[14] និង (៣) ស្នើឡើងនូវអនុសាសន៍ដោយមិនត្រឹមត្រូវថា ការស៊ើបសួរតាមវិធាន៣៥ មិនអាចត្រូវបានផ្ដួចផ្ដើមគំនិតដោយអង្គជំនុំជម្រះ ទៅតាមសំណើរបស់ភាគីណាមួយបានទេ("ទង្វើករណ៍ទីបី")[15]។ ក្នុងបណ្ដឹងសាទុក្ខក៏មានចោទប្រកាន់ផងដែរអំពីកំហុស ដែលអាចឲ្យយល់ដឹងបានមួយនៅក្នុងការអនុវត្តន៍ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដោយសារតែខកខានមិនបានចាត់តាំង "ឲ្យមានការវាយតម្លៃពីភវនីយហេតុឲ្យបានត្រឹមត្រូវ" ទៅលើឯកសារនានាដែលទាក់ទងនឹងសំណុំរឿងលេខ០០៣ និង០០៤ និងឲ្យមានការវាយតម្លៃទៅលើការលើកឡើងអះអាងរបស់មេធាវីការពារក្ដីដែលទាក់ទងទៅនឹងការចោទប្រកាន់ស្ដីពីការជ្រៀតជ្រែកនៅក្នុងសំណុំរឿងលេខ០០២ "ទង្វើករណ៍ទីបួន")[16]។

៩- ភាពអាចទទួលយកបាននៃ*បណ្ដឹងសាទុក្ខណាមួយ* អង្គជំនុំជម្រះតោងតែដាក់ឲ្យស្ថិតនៅក្រោម*លក្ខខណ្ឌតម្រូវតាមទម្រង់ផ្លូវការ*ចំនួនពីរដែលដើមបណ្ដឹងសាទុក្ខជាអ្នក"កំណត់បញ្ជាក់ច្បាស់" អំពីការចោទប្រកាន់ស្ដីពីកំហុសនីមួយៗនៅក្នុងពេល"លើកឡើងអំពីទង្វើករណ៍នៃការប្ដឹងសាទុក្ខ"អំពីសេចក្ដី

[13] ឯកសារលេខ **E116/1/1** បណ្ដឹងសាទុក្ខ កំណត់សម្គាល់លេខ៤*ខាងដើម* ត្រង់កថាខណ្ឌទី២១ និង២៤។

[14] ឯកសារលេខ **E116/1/1** បណ្ដឹងសាទុក្ខ កំណត់សម្គាល់លេខ៤*ខាងដើម* ត្រង់កថាខណ្ឌទី២៥ ដល់៣១។ មេធាវីការពារក្ដីលើកឡើងថាមានការចោទប្រកាន់អំពីការខកខានជាច្រើនដោយអង្គជំនុំជម្រះសាលាដំបូង "ដែលស្មើនឹង*កំហុសលើ បញ្ហា*ផ្នែកច្បាប់..."(ត្រង់កថាខណ្ឌទី៣១)។ ហេតុនេះ, នៅក្នុងចម្លើយតបនេះ, សហព្រះរាជអាជ្ញាលើកឡើងអំពីការចោទប្រកាន់អំពី ការខកខាននានាដែលស្ថិតនៅវង្វង់ក្នុងក្របខណ្ឌនៃកំហុសខាងអង្គច្បាប់តែមួយគត់។

[15] ឯកសារលេខ **E116/1/1** បណ្ដឹងសាទុក្ខ កំណត់សម្គាល់លេខ៤*ខាងដើម* ត្រង់កថាខណ្ឌទី៣៥។

[16] ឯកសារលេខ **E116/1/1** បណ្ដឹងសាទុក្ខ កំណត់សម្គាល់លេខ៤*ខាងដើម* ត្រង់កថាខណ្ឌទី៣២-៣៤។

សំអាងផ្សេងៗសម្រាប់គាំទ្រដល់ការលើកឡើងទាំងនេះ"[17]និងអំពីបង្ហាញអត្ថសញ្ញាណពីការរកឃើញនានា និងអំពីសេចក្តីសម្រេចដែលត្រូវបានប្រឆាំងជំទាស់ ដោយមានការយោងជាក់លាក់ទៅលើលេខទំព័រនិងលេខកថាខណ្ឌនានានៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង"[18]។ សូម្បីតែក្នុងករណីបើសិនជាអង្គជំនុំជម្រះបញ្ចុះនូវលក្ខខណ្ឌតម្រូវទាំងនេះដើម្បីឱ្យស្របទៅតាមខ្លឹមសារដែលមិនសូវតឹងរ៉ឹងដែលត្រូវបានប្រកាន់យកនៅក្នុងវិធានស្តីពីនីតិវិធីនិងភស្តុតាងរបស់តុលាការ *ពិសេស*នានា[19] និងលក្ខខណ្ឌក្នុងកម្រិតទាបនៃចំណុចចាប់ផ្តើមនៃភាពជាក់លាក់សម្រាប់ទឡ្ហីករណ៍នានាដែលត្រូវបានគេយកមកប្រើនៅក្នុងយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការICTY និងតុលាការ ICTR[20]ក្តីក៏ភាពជាក់លាក់ដូចជាការចោទប្រកាន់ អំពីកំហុសផ្សេងៗនឹងមិនមានន័យថាជាចំណុចចាប់ផ្តើមសម្រាប់ភាពអាចទទួលយកបានទាល់តែសោះ លុះត្រាតែ អង្គជំនុំជម្រះតម្រូវនៅក្នុងកម្រិតអប្បបរមាថា ទឡ្ហីករណ៍នៃការប្តឹងសាទុក្ខមានមូលដ្ឋានខាងអង្គហេតុដែលអាចឱ្យយល់ដឹងបាន នៅក្នុងសេចក្តីសម្រេចដែលកំពុងតវ៉ា។

១០- សហព្រះរាជអាជ្ញាសូមលើកជាសេចក្តីសន្និដ្ឋានថា ទាំងទឡ្ហីករណ៍ទីមួយក្តីឬទាំងទឡ្ហីករណ៍ទីបីនៃការប្តឹងសាទុក្ខក្តី គឺសុទ្ធតែមិនមានមូលដ្ឋានខាងអង្គហេតុនៅក្នុងសេចក្តីសម្រេចដែលកំពុងតវ៉ាទាំងអស់។ លើសពីនេះ ទឡ្ហីករណ៍ទីបីហាក់ដូចជាមានចេតនាចង់ធ្វើជាតំណាងដែលខុសជួសមុខឱ្យការវែកញែកហេតុផលរបស់អង្គជំនុំជម្រះសាលាដំបូង ប្រយោជន៍នឹងប្រឌិតឡើងជាបណ្តឹងសាទុក្ខមួយដែលគ្មានមូលដ្ឋានទាំងស្រុង។

---

[17] វិធាន១០៥ (២)នៃវិធានផ្ទៃក្នុង។

[18] វិធាន១០៥ (៥)នៃវិធានផ្ទៃក្នុង។

[19] សូមអាន ឧទាហរណ៍ដូចជា វិធាន១០៨ នៃវិធានស្តីពីនីតិវិធីនិងភស្តុតាងនៃតុលាការ ICTY, ដែលតម្រូវឱ្យដើមបណ្តឹងសាទុក្ខ "បញ្ជាក់ពីខ្លឹមសារនៃការចោទប្រកាន់នានាអំពីការមានកំហុស"។

[20] សូមអាន ឧទាហរណ៍ដូចជា *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Anto Furundžija*, សំណុំរឿងលេខ IT-95-17/1-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី២១ កក្កដា២០០០ ត្រង់កថាខណ្ឌទី៣៥។ *ករណីរឿងក្តីរបស់ François Karera ទល់នឹង រដ្ឋអាជ្ញា*, សំណុំរឿងលេខ ICTR-01-74-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR), ចុះថ្ងៃទី២ កុម្ភៈ ឆ្នាំ២០០៩ ត្រង់កថាខណ្ឌទី៨, ដែលកត់សម្គាល់ថា ដើមបណ្តឹងសាទុក្ខ "ត្រូវតែត្រៀមលក្ខណៈក្នុងការបញ្ជូនសេចក្តីសំអាងហេតុជាមុន ដើម្បីគាំទ្រដល់ការតតល់គ្នា" ថាកំហុសខាងអង្គច្បាប់បានកើតឡើង។ សូមអានផងដែរ *ករណីរឿងក្តីរបស់ Tihomir Blaškić ទល់នឹង រដ្ឋអាជ្ញា*, សំណុំរឿងលេខ IT-95-14-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី២៩ កក្កដា ២០០៤ ត្រង់កថាខណ្ឌទី១៤, ដែលតម្រូវឱ្យភាគីដែលចោទប្រកាន់អំពីកំហុសខាងអង្គច្បាប់ "បង្ហាញនូវសេចក្តីសំអាងនានាសម្រាប់គាំទ្រដល់ការលើកឡើងអះអាងរបស់ខ្លួន"។

### *i. ទឡ្ហីករណ៍ទីមួយសម្រាប់ការប្តឹងសាទុក្ខគ្មានមូលដ្ឋានខាងអង្គហេតុ នៅក្នុងសេចក្តីសម្រេចដែលកំពុងតវ៉ាឡើយ*

១១- ក្នុងការបញ្ជូនទឡ្ហីករណ៍ទីមួយ មេធាវីការពារក្តីរបស់ នួន ជា ចោទប្រកាន់ថា សេចក្តីសម្រេចដែលកំពុងតវ៉ា "គ្រាន់តែធ្វើមិនដឹងមិនឮ"[21]ចំពោះ "ការលើកឡើងអះអាងផ្សេងៗដោយលំអិត និងដែលមានសេចក្តីថ្លែងសំអាងយ៉ាងច្បាស់"របស់មេធាវីការពារក្តី[22] អំពីការចោទប្រកាន់ពីរអំពីការជ្រៀតជ្រែកដោយផ្ទាល់ដោយរាជរដ្ឋាភិបាលកម្ពុជា("RGC")នៅក្នុងសំណុំរឿងលេខ០០២ និងថា"អំពើដែលធ្វើឡើងដោយសារការធ្វេសប្រហែសនេះគឺវាស្មើគ្នានឹងកំហុសខាងអង្គច្បាប់-*ដោយសារអង្គហេតុនេះផ្ទាល់តែម្តង*"[23]។ ការចោទប្រកាន់ទាំងពីរនេះគឺទាក់ទងទៅនឹងការបរាជ័យរបស់សហចៅក្រមស៊ើបអង្កេតក្នុងការព្យាយាម ដើម្បីឲ្យបានទទួលនូវការផ្តល់សក្ខីកម្មពីសម្តេចព្រះរាជបីតាព្រះបាទនរោត្តម សីហនុ ហើយនិងការរារាំងចំពោះដីកាកោះ "អ្នករនុកក្នុងប្រាំមួយនាក់"[24]។ សហព្រះរាជអាជ្ញាសូមលើកឡើងថា គឺមិនមានមូលដ្ឋានខាងអង្គហេតុនៅក្នុងសេចក្តីសម្រេចដែលកំពុងតវ៉ា ដើម្បីធ្វើការបញ្ជាក់អះអាងបានថា អង្គជំនុំជម្រះសាលាដំបូងបាន"ធ្វើមិនដឹងមិនឮ"ចំពោះសារណាជាក់លាក់ទាំងនេះរបស់មេធាវីទេ។ ដូចដែលអង្គជំនុំជម្រះបានថ្លែងដោយច្បាស់ៗ នៅក្នុងសេចក្តីសម្រេចដែលកំពុងតវ៉ារួចហើយថា ការចោទប្រកាន់ទាំងពីរស្តីពីការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងសំណុំរឿងលេខ០០២ គឺត្រូវបានមេធាវីការពារក្តីលើកឡើងនៅក្នុងអញ្ញត្រកម្មបឋមរួមរបស់ខ្លួន[25] ហើយជាការលើកឡើងដោយច្រំដែលៗទៀត នៅក្នុងសំណើសុំលើកទីមួយ[26]- ការសម្រេចបញ្ចប់នូវសំណើនេះ គឺជាមូលហេតុតែមួយគត់នៃបណ្តឹងសាទុក្ខនេះ។ ជាងនេះទៅទៀត សេចក្តីសម្រេចដែលកំពុងតវ៉ាថែមទាំងសង្ខេបនូវខ្លឹមសារនៃសារណារបស់មេធាវីការពារក្តី ដែលទាក់ទងនឹងករណីការ

---

[21] ឯកសារលេខ **E116/1/1** បណ្តឹងសាទុក្ខ កំណត់សម្គាល់លេខ៤*ខាងដើម* ត្រង់កថាខណ្ឌទី២៤។

[22] *ដូចគ្នានឹងខាងលើ*។

[23] *ដូចគ្នានឹងខាងលើ*។

[24] *ដូចគ្នានឹងខាងលើ*។

[25] ឯកសារលេខ **E116** សេចក្តីសំរេចដែលកំពុងតវ៉ា, កំណត់សម្គាល់លេខ១ ខាងដើម ត្រង់កថាខណ្ឌទី៦, ដែលអង្គជំនុំជម្រះសាលាដំបូងយោងទៅលើឯកសារលេខ **E51/3** អញ្ញត្រកម្មបឋមរួម, ចុះថ្ងៃទី២៥ កុម្ភៈ ២០១១ ត្រង់កថាខណ្ឌទី៦, ១០-១៤ និងទី៥៧ ("អញ្ញត្រកម្មបឋម")

[26] ឯកសារលេខ **E116** *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី១០, ដែលអង្គជំនុំជម្រះសាលាដំបូងថ្លែងថា "នៅក្នុងសំណើសុំអនុលោមតាមវិធាន៣៥លើកទីមួយរបស់ខ្លួន ជនជាប់ចោទបានយោងទៅលើការចោទប្រកាន់អំពីការជ្រៀតជ្រែកចូលក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់ RGC ដោយបានរៀបរាប់នៅក្នុងអញ្ញត្រកម្មរបស់ខ្លួន"។

ជ្រៀតជ្រែករបស់រដ្ឋាភិបាលកម្ពុជាទាំងពីរករណីនេះទៀតផង[27]។ អង្គជំនុំជម្រះសាលាដំបូងបានបន្តផ្ចិតទៅទៀតបន្ទាប់ពីកថាខណ្ឌទាំងពីរនៃការវែកញែកហេតុផលដោយលំអិតនេះ ដើម្បីរកឱ្យឃើញនូវផ្នែកទាំងឡាយនៅក្នុងអញ្ញត្រកម្មបឋមរបស់មេធាវី ដែលជាប់ទាក់ទងនឹង "ការជ្រៀតជ្រែកនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការ" ដែលមិនអាចឱ្យទទួលយកបាននេះ[28]។ ហេតុដូចនេះ ទឡ្ហីករណ៍ទីមួយនៃការប្តឹងឧទ្ធរណ៍ត្រូវអាស្រ័យទាំងស្រុងទៅលើមូលដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមិនបាន *ពិនិត្យពិចារណាឡើងវិញ* លើការចោទប្រកាន់ទាំងពីរស្តីពីការជ្រៀតជ្រែករបស់RGC ដែលត្រូវបានពិនិត្យពិចារណានិងសម្រេចរួចហើយថា មិនអាចទទួលយកបានទេ កាលពីពេលសម្រេចបញ្ចប់លើសំណើសុំលើកទីមួយនេះ។

១២- សំណើសុំលើកទីមួយត្រូវបានដាក់នៅក្នុងខែមេសា ឆ្នាំ២០១១ គឺជាងពីរខែបន្ទាប់ពីការដាក់អញ្ញត្រកម្មបឋម។ នៅក្នុងសារណាទាំងពីរនេះយោងទៅលើតែការចោទប្រកាន់ពីការជ្រៀតជ្រែករបស់ RGC ទាំងពីរករណីនៅក្នុងសំណុំរឿងលេខ០០២ ហើយបានលើកសំអាងទៅលើសំណើសុំកិច្ចស៊ើបសួរឆ្នាំ២០០៩ របស់មេធាវី នួន ជា ដែលបានដាក់ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលសំណើនោះក៏លើកយោងទៅលើការចោទប្រកាន់ដដែលលដូចគ្នាដែរ[29]។ ដោយយល់ឃើញថាការដាក់សារណាមានភាពច្រំដែលៗ អំពីការចោទប្រកាន់ពីរដដែលៗជូនទៅអង្គជំនុំជម្រះតែមួយជាមួយគ្នានោះ គឺមិនមានមូលដ្ឋានខាងអង្គហេតុដែលអាចយល់ដឹងបានសម្រាប់កំហុសខាងអង្គច្បាប់នោះឡើយ ដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើកំណត់សំគាល់ និងធ្វើជាសេចក្តីសង្ខេបការចោទប្រកាន់ដូចគ្នាដដែលៗទាំងពីរនេះ ប៉ុន្តែសម្រេចចិត្តថាមិនធ្វើការសម្រេចបញ្ចប់ជាថ្មីម្តងទៀតលើការចោទប្រកាន់ដដែលៗពីរលើកមកហើយនៅក្នុងសេចក្តីសម្រេចដែលកំពុងតវ៉ានេះឡើយ។

---

[27] ឯកសារលេខ **E116** *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី៦ និងទី១០។

[28] ឯកសារលេខ **E116** *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី១៧។

[29] សូមអានផងដែរ ឯកសារលេខ **E51/3** អញ្ញត្រកម្មបឋម, កំណត់សម្គាល់លេខ ២៥ *ខាងដើម* ត្រង់កថាខណ្ឌទី៦-៧។ ឯកសារលេខ **D254** សំណើសុំកិច្ចស៊ើបសួរ, ចុះថ្ងៃទី៣០ វិច្ឆិកា ២០០៩ ត្រង់កថាខណ្ឌទី៥។

១៣- សហព្រះរាជអាជ្ញាសង្កេតឃើញថា នៅក្នុងរឿងនេះ ដែលការដាក់បញ្ចូលគ្នាដោយយោងទៅលើសេចក្តីសំអាងនានាកាលពីមុន-ដែលជាការអនុវត្តន៍ដែលគាំទ្រយ៉ាងខ្លាំងដោយមេធាវីរបស់ នួន ជា[30] គឺជាមធ្យោបាយនៃការបំពេញឲ្យខ្លីដែលជាការសមស្រប សម្រាប់តែករណីបើសិនជាបញ្ហាណាមួយដែលបានលើកឡើងនៅក្នុងសារណាកាលពីមុន ដែលកំពុងរង់ចាំនៅចំពោះមុខអង្គជំនុំជម្រះតែប៉ុណ្ណោះ។ ការយោងនេះមិនអាចប្រើសម្រាប់ធានាឲ្យមានការពិនិត្យពិចារណាឡើងវិញដដែលៗលើបញ្ហាទាំងឡាយដែលត្រូវបានចូលជាកម្មវត្ថុនៃការពិនិត្យពិចារណា និងសម្រេចរបស់តុលាការបានឡើយ។ ការដែលគ្រាន់តែប្រមែរប្រមូលនូវលេខយោងជើងទំព័រតែប៉ុណ្ណោះនោះមិនអាចបំពេញគ្រប់តាមចំណុចចាប់ផ្តើមណាមួយនៃភាពជាក់លាក់ដែលលក្ខខណ្ឌបានតម្រូវសម្រាប់ភាពអាចទទួលយកបាននៃទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខបានទេ។

### ii. *ទឡ្ហីករណ៍ទីបីសម្រាប់ការប្តឹងសាទុក្ខគ្មានមូលដ្ឋានខាងអង្គហេតុនៅក្នុងសេចក្តីសម្រេចដែលកំពុងតវ៉ាឡើយ*

១៤- ក្នុងការបញ្ជូនទឡ្ហីករណ៍ទីបី មេធាវីការពារក្តីរបស់ នួន ជា ចោទប្រកាន់ថា សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ[31]នៅក្នុងលេខយោងជើងទំព័រមួយ ("កត់សំគាល់ថាវិធាន៣៥នៃវិធានផ្ទៃក្នុងមិនបានចែងពីការផ្តួចផ្តើមគំនិតក្នុងការបើកកិច្ចស៊ើបសួរតាមសំណើរបស់ភាគីណាមួយនោះឡើយ")[32] ដែលស្មើគ្នានឹងការរកឃើញមួយដែលថា មេធាវីការពារក្តីរបស់ភាគីណាមួយមិនអាច "ធ្វើឲ្យអង្គជំនុំជម្រះផ្លាស់ប្តូរជាវិជ្ជមានឲ្យមានសំណងជួសជុលតាមវិធាន៣៥នៃវិធានផ្ទៃក្នុងបានឡើយ"[33] ហើយថាការរកឃើញនោះ គឺជាកំហុសមួយខាងអង្គច្បាប់ដែលធ្វើឲ្យមោឃភាពដល់សេចក្តីសម្រេចដែលកំពុងមានបញ្ហា។ សហព្រះរាជអាជ្ញា សូមបញ្ជាក់អះអាងថា អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែមិនបានរកឃើញណាមួយបែបដូចនេះទេ។ អង្គជំនុំជម្រះសាលាដំបូងបានដកស្រង់ខ្លឹមសារនៃវិធាន៣៥.២នៃ

---

[30] សូមអាន *ឧទាហរណ៍ដូចជា* ឯកសារលេខ **E116/1/1** បណ្តឹងសាទុក្ខ កំណត់សម្គាល់លេខ៤*ខាងដើម* ត្រង់កថាខណ្ឌទី២ និង៣៥។ ឯកសារលេខ **E82** សំណើសុំកិច្ចស៊ើបសួរលើកទីមួយ, កំណត់សម្គាល់លេខ២*ខាងដើម* ត្រង់កថាខណ្ឌទី១៨។

[31] **D158/5/1/15** សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីសំណើសុំកិច្ចស៊ើបសួរលើកទី១១ របស់ជនត្រូវចោទ, ចុះថ្ងៃទី១៨ សីហា ២០០៩ ត្រង់កថាខណ្ឌទី២៩។ សូមអាន ឯកសារលេខ **E116/1/1** បណ្តឹងសាទុក្ខ ត្រង់លេខ ៩៧។

[32] *ដូចគ្នានឹងខាងលើ*។

[33] ឯកសារលេខ **E116/1/1** បណ្តឹងសាទុក្ខ, កំណត់សម្គាល់លេខ៤ *ខាងដើម* ត្រង់កថាខណ្ឌទី៣៥។

វិធានផ្ទៃក្នុងដើម្បីបញ្ជាក់ថាការរកឃើញរបស់ខ្លួនដែលថា "ការស៊ើបសួរអនុលោមតាមវិធាននេះអាចនឹងដឹកនាំធ្វើឱ្យប្រកបដោយអត្ថន័យទៅបាន ដោយស្ថាប័នណាមួយរបស់តុលាការលុះត្រាតែស្ថាប័ននោះត្រូវបានគេប្ដឹងអំពីករណីនោះប៉ុណ្ណោះ"។ នៅចំពោះមុខរបស់ខ្លួន សេចក្ដីសម្រេចដែលកំពុងតវ៉ា មិនអាចត្រូវបានយល់ថាជាការហាមឃាត់ភាគីណាមួយ មិនឱ្យស្នើសុំទៅសមត្ថកិច្ចណាមួយរបស់តុលាការ ដើម្បីកុំឱ្យធ្វើការផ្ដួចផ្ដើមគំនិតបើកកិច្ចស៊ើបសួរណាមួយអនុលោមតាមវិធាន៣៥នៃវិធានផ្ទៃក្នុងនោះឡើយ។ ហេតុដូចនេះ ទឡ្ហីករណ៍ទីបី គ្មានមូលដ្ឋានភ័ស្តុតាងនៅក្នុងសេចក្ដីសម្រេចដែលកំពុងតវ៉ាទេ។

### iii. *ទឡ្ហីករណ៍ទីបីនៃការប្ដឹងសាទុក្ខមានចេតនាចង់ធ្វើជាតំណាងខុសជួសឱ្យការវែកញែកហេតុផលរបស់អង្គជំនុំជម្រះសាលាដំបូង*

១៥- លក្ខណៈដែលគ្មានមូលដ្ឋានទាំងស្រុងនៃទឡ្ហីករណ៍ទីបី ដែលគួបផ្សំគ្នាជាមួយនឹងប្រការជាក់ស្ដែងដែលថា សំណើសុំលើកទីពីររបស់ នួន ជា - ដែលតាមរយៈនេះ មេធាវីរបស់គាត់បានធ្វើជាវិជ្ជមានឱ្យអង្គជំនុំជម្រះផ្លាស់ប្ដូរមករកសំណងជួសជុលតាមវិធាន៣៥នៃវិធានផ្ទៃក្នុងវិញ- ត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួលយក ហើយបានពិនិត្យពិចារណាតាមផ្លូវតុលាការនៅក្នុងសេចក្ដីសម្រេចដែលកំពុងតវ៉ាដែលឱ្យដឹងថាមេធាវីការពារបានមានចេតនាចង់ធ្វើជាតំណាងខុសជួសឱ្យការវែកញែកហេតុផលរបស់អង្គជំនុំជម្រះសាលាដំបូង ប្រយោជន៍ដើម្បីប្រឌិតឡើងនូវទឡ្ហីករណ៍ក្នុងការប្ដឹងសាទុក្ខប្រឆាំងនឹងករណីនេះ។

១៦- ផ្អែកលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញា សូមជូនជាសេចក្ដីសន្និដ្ឋានថា អង្គជំនុំជម្រះគួរតែសម្រេចថា មិនអាចទទួលយកបានទាំងទឡ្ហីករណ៍សម្រាប់ការប្ដឹងឧទ្ធរណ៍ទីមួយ និងទាំងទីបី ដោយសារតែខ្វះមូលដ្ឋានខាងអង្គហេតុនៅក្នុងសេចក្ដីសម្រេចដែលកំពុងតវ៉ា ដែលជាការបរាជ័យដោយសារតែបំពេញមិនបានទៅតាមលក្ខខណ្ឌនៃចំណុចចាប់ផ្ដើមណាមួយស្ដីពីភាពជាក់លាក់ថាតើលក្ខខណ្ឌនៃចំណុចចាប់ផ្ដើមនៃភាពអាចទទួលយកបានដែលច្បាស់លាស់នៅក្នុងវិធាន១០៥នៃវិធានផ្ទៃក្នុង ឬមួយក៏លក្ខខណ្ឌនៃចំណុចចាប់ផ្ដើមកម្រិតទាបជាងដែលបានឆ្លុះបញ្ចាំងនៅក្នុងយុត្តិសាស្ត្រនៃតុលាការ *ពិសេស* នានា។

## ២. បណ្តឹងសាទុក្ខខកខានក្នុងការបំពេញទៅតាមបទដ្ឋានស្តីពីការពិនិត្យ ឡើងវិញលើបណ្តឹងសាទុក្ខ

### i. *បទដ្ឋានស្តីពីការពិនិត្យឡើងវិញតម្រូវឲ្យដើមបណ្តឹងសាទុក្ខបង្ហាញថាការចោទប្រកាន់ណាមួយអំពីកំហុសខាងអង្គច្បាប់ធ្វើឲ្យមោឃៈដល់សេចក្តីសម្រេចដែលកំពុងតវ៉ា*

១៧- វិធាន១០៤.១នៃវិធានផ្ទៃក្នុង បានចែងអំពីយុត្តាធិការលើបណ្តឹងសាទុក្ខជាទូទៅរបស់អង្គជំនុំជម្រះដែលត្រូវបានកម្រិតត្រឹមតែ៖(១)កំហុសលើបញ្ហាខាងអង្គច្បាប់ ដែលនាំឲ្យមោឃៈដល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង (២) កំហុសលើបញ្ហាខាងអង្គហេតុ ដែលនាំឲ្យមានភាពមិនយុត្តិធម៌ ឬ (៣) សម្រាប់បណ្តឹងសាទុក្ខភ្លាមៗ គឺមានតែកំហុសដែលអាចឲ្យយល់ដឹងបានដែលស្តែង

ចេញពីការអនុវត្តឆន្ទានុសិទ្ធិដោយអង្គជំនុំជម្រះសាលដំបូងប៉ុណ្ណោះដែលអាចនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់ដើមបណ្តឹងសាទុក្ខ[34]។ បទដ្ឋានច្បាប់ទាំងបីនេះត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញ*ដូចគ្នាគ្រប់ម៉ាត់ទាំងអស់*នៅក្នុងវិធាន១០៥.២ ដែលចែងពីលក្ខខណ្ឌតម្រូវសម្រាប់ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ និងដោយចែងមិនចំៗអំពីបទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខជាធរមាន។ ហេតុនេះ អង្គជំនុំជម្រះអាចអនុញ្ញាតឲ្យធ្វើបណ្តឹងសាទុក្ខនេះបានតែត្រឹមកម្រិតដែលខ្លួនបានរកឃើញតែប៉ុណ្ណោះ ដោយផ្អែកលើការថ្លឹងថ្លែងអំពីភវនីយភាព៖ (១)កំហុសលើបញ្ហាខាងអង្គច្បាប់ដែលនាំឲ្យមោឃៈដល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង (២)កំហុសលើបញ្ហាខាងអង្គហេតុ ដែលនាំឲ្យមានភាពមិនយុត្តិធម៌ ឬ (៣) កំហុសដែលអាចឲ្យយល់ដឹងបានដែលស្តែងចេញពីការអនុវត្តឆន្ទានុសិទ្ធិ ដោយអង្គជំនុំជម្រះសាលដំបូងដែលអាចនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់ដើមបណ្តឹងសាទុក្ខ។

១៨- អង្គជំនុំជម្រះនេះបានបំភ្លឺអំពីវិសាលភាពនៃវិធាន១០៤.១នៃវិធានផ្ទៃក្នុង ដោយកត់សំគាល់ថាកំហុសដែលឲ្យយល់អាចដឹងបាននៅក្នុងការអនុវត្តន៍ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង“គឺមិន

[34] វិធាន១០៤ (១) នៃវិធានផ្ទៃក្នុង។

...បង្កើតជាទម្លាប់ករណ៍ផ្តាច់មុខសម្រាប់បណ្តឹងសាទុក្ខភ្លាមៗនោះទេ”[35]។ អង្គជំនុំជម្រះនេះក៏បានធ្វើការបញ្ជាក់សារជាថ្មីអំពីសិទ្ធិអំណាចដែលមានការកម្រិតកំណត់ក្នុងការពិនិត្យឡើងវិញ លើបណ្តឹងសាទុក្ខ ដែលមានភាពខុសគ្នាពីសិទ្ធិអំណាចដែលទូលំទូលាយជាងនេះណាមួយរបស់អង្គជំនុំជម្រះដទៃៗទៀត[36]។ ជាងនេះទៅទៀត នៅពេលកំណត់សម្រេចអំពីវិសាលភាពដ៏តូចចង្អៀតនៃការពិនិត្យទើងវិញលើបណ្តឹងសាទុក្ខសមស្រប “អង្គជំនុំជម្រះតុលាការកំពូល គឺជាសាលាឧទ្ធរណ៍ចុងក្រោយគេបង្អស់ដែលពិនិត្យឡើងវិញលើសេចក្តីសម្រេចដែលកំពុងតវ៉ាដែលស្ថិតក្នុងរង្វង់នៃទម្លាប់ករណ៍នៃការប្តឹងសាទុក្ខនិងដែលស្របគ្នាជាមួយនឹងទិសដៅនៃការប្តឹងសាទុក្ខ”[37]។ នោះគឺថា វិសាលភាពនៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខរបស់ខ្លួន គឺត្រូវបានកំណត់និយមន័យដោយបណ្តឹងសាទុក្ខខ្លួនឯងតែម្តង។ នេះគឺមិនមែនជាការប្រទានចោលជាមុន មិនឱ្យអង្គជំនុំជម្រះចូលរួមនៅក្នុងការវែកញែកហេតុផលរបស់ខ្លួនផ្ទាល់នោះទេ ក៏ប៉ុន្តែបញ្ហាដែលកំពុងតែត្រូវបានពិនិត្យពិចារណាដោយអង្គជំនុំជម្រះលើបណ្តឹងសាទុក្ខនោះត្រូវតែជាកម្មវត្ថុនៃបណ្តឹងសាទុក្ខ ហើយដែលត្រូវតែមានការរកឃើញផ្នែកអង្គហេតុដែលអនុញ្ញាតឱ្យមានការស្វែងរកសុំការកែតម្រូវដោយដើមបណ្តឹងសាទុក្ខ[38]។

១៩- តុលាការ*ពិសេស*នានាបានអនុម័តយកនូវវិធីសាស្ត្រ ដែលមានការកម្រិតព្រំដែនមួយស្រដៀងគ្នានេះដែរ នៅពេលចូលរួមនៅក្នុងការពិនិត្យឡើងវិញថ្នាក់បណ្តឹងសាទុក្ខដែលគាំទ្រចំពោះការយល់ឃើញថា មុខងារជាចំបងនៃយុត្តាធិការលើបណ្តឹងសាទុក្ខ គឺសម្រាប់ធ្វើការកែប្រែ។ លក្ខន្តិកៈរបស់តុលាការ ICTY និង ICTR បានគូសបញ្ជាក់ពីបទដ្ឋាននៃការពិនិត្យឡើងវិញដែលមានការកម្រិតជាខ្លាំងដែលត្រូវបានសង្កត់ធ្ងន់នៅក្នុងយុត្តិសាស្ត្រនៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍ថា៖ “...រីឯអង្គជំនុំជម្រះនានា*អាច* យល់ឃើញថា មានការចាំបាច់ត្រូវលើកឡើងអំពីបញ្ហានានា [ពួកគេ] *ក៏អាច* ប្រកែកមិនព្រមធ្វើដូច្នេះ*ផងដែរ*”[39]។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាឧទ្ធរណ៍នានា “នឹងមិនពិចារណា

---

[35] ឯកសារលេខ **E50/3/1/4**, សាលដីកាសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីពាក្យសុំដោះលែងជាបន្ទាន់។

[36] *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី ៥៣។

[37] *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី ៥២។

[38] *ដូចគ្នានឹងខាងលើ* ។

[39] លក្ខន្តិកៈរបស់តុលាការ ICTY ។ លក្ខន្តិកៈរបស់តុលាការ ICTR ។ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Jean-Paul Akayesu*, សំណុំរឿងលេខ ICTR-96-4-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR), ចុះថ្ងៃទី១ មិថុនា ២០០១ ត្រង់កថាខណ្ឌទី២៤ [ដែលសង្កត់ន័យបន្ថែមដោយអក្សរទ្រេត]។ ដែលបានដកស្រង់សំដីដោយមានការយល់ព្រមពីក្នុង *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Milorad Krnojelac*, សំណុំរឿងលេខ IT-97-25-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី១៧ កញ្ញា ២០០៣ ត្រង់កថាខណ្ឌទី៨។

លើរាល់បញ្ហាទាំងឡាយដែលមានសារៈសំខាន់ទូទៅនោះទេ។ តាមការពិត បញ្ហាទាំងឡាយដែលបាន លើកឡើងគោងតែជាផលប្រយោជន៍ដល់ការអនុវត្តន៍ច្បាប់របស់តុលាការ ហើយគោងតែមានចំណង ទាក់ទងគ្នាជាមួយនឹងករណីរឿងដែលនៅជាប់ក្បែរគ្នា”[40]។

២០- នៅក្នុងការអនុវត្តន៍របស់តុលាការ*ពិសេស*នានា បទដ្ឋានជាក់លាក់នៃការពិនិត្យឡើងវិញអំពីកំហុស នានាផ្នែកអង្គច្បាប់ ឆ្លុះបញ្ចាំងឲ្យឃើញពីបទដ្ឋានដែលនៅក្នុងវិធាន១០៥ ដែលបានចែងខាងលើ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍មានយុត្តាធិការតែទៅលើ “កំហុសខាងអង្គច្បាប់ដែលនាំឲ្យមោឃៈ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង”[41]ប៉ុណ្ណោះគត់។ ដោយមានការជាប់ជំពាក់ដែល ចាំបាច់ មិនមែនគ្រប់រាល់កំហុសខាងអង្គច្បាប់ទាំងអស់ដែលបំពេញបានទៅតាមបទដ្ឋាននៃការ ពិនិត្យឡើងវិញនោះទេ។ មានកំហុសខាងអង្គច្បាប់មួយចំនួនធំដែលដោយសារតែលក្ខណៈ ឬផល វិបាកនានារបស់វា គឺមិនធ្វើឲ្យមោឃៈដល់សេចក្តីសម្រេចរបស់របស់អង្គជំនុំជម្រះសាលាដំបូងនោះ ឡើយ។

២១- ឧទាហរណ៍ដូចជា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR បានទទួលស្គាល់ថា អង្គជំនុំ ជម្រះសាលាដំបូង “បានប្រព្រឹត្តកំហុសខាងអង្គច្បាប់មួយដែលអាចឲ្យយល់ដឹងបាន” ក៏ប៉ុន្តែដោយ សារតែកំហុសនោះមិនបាន “ធ្វើឲ្យមោឃៈដល់[...]សាលក្រមរបស់សាលាដំបូង”ដោយប្រសិទ្ធភាព នោះ ចំណុចពិសេសនៃបណ្តឹងសាទុក្ខក៏ត្រូវបានបដិសេធ[42]។ ក្នុងករណីនេះដើមបណ្តឹងសាទុក្ខ ឈ្មោះ*Siméon Nchamihigo*បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានមានកំហុសដោយ ចាប់ផ្តើមសវនាការជំនុំជម្រះក្តីលើរូបគាត់ នៅមុនពេលធ្វើការដោះស្រាយលើរាល់បញ្ហាដែលនៅ សេសសល់ទាំងអស់ដែលទាក់ទិន នឹងវិការៈខាងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ - ដែលជា

---

[40] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Jean-Paul Akayesu*, សំណុំរឿងលេខ ICTR-96-4-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR), ចុះថ្ងៃទី១ មិថុនា ២០០១ ត្រង់កថាខណ្ឌទី២៤ ។ ដែលបានដកស្រង់សំដីដោយមានការយល់ព្រមពីក្នុង*Milorad Krnojelac*, សំណុំរឿងលេខ IT-97-25-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី១៧ កញ្ញា២០០៣ ត្រង់កថាខណ្ឌទី៨។

[41] *ករណីរឿងក្តីរបស់ François Karera ទល់នឹង រដ្ឋអាជ្ញា*, ឯកសារលេខ ICTR-01-74-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR), ចុះថ្ងៃទី២ កុម្ភៈ ២០០៩ ត្រង់កថាខណ្ឌទី៧។

[42] *ករណីរឿងក្តីរបស់ Siméon Nchamihigo ទល់នឹង រដ្ឋអាជ្ញា*, សំណុំរឿងលេខ ICTR-2001-63-A,សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR), ចុះថ្ងៃទី១៨ មីនា ២០១០ ត្រង់កថាខណ្ឌទី៣១-៣២។

បញ្ហាស្នូលមួយជាពិសេសចំពោះសិទ្ធិរបស់មេធាវីការពារក្ដី ដោយសារតែលក្ខណៈនៃការបើកឱ្យមានការតទល់គ្នាដែលមានភាពលប់លើគេនៃដំណើរការនីតិវិធីនៅមុនពេលសវនាការ នៅតាមតុលាការ*ពិសេស*នានា។ ជាការឆ្លើយតប ខាងអយ្យការបានពោលអះអាងថា ដើមបណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញឱ្យឃើញថាមានការប៉ះពាល់ដល់លទ្ធភាពរបស់ដើមបណ្ដឹងសាទុក្ខក្នុងការត្រៀមរៀបចំសារណាសម្រាប់ការការពារក្ដីឱ្យបានប្រកបដោយប្រសិទ្ធភាព។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា តាមពិតទៅ អង្គជំនុំជម្រះសាលាដំបូងមិនបានរំលោភលើបទបញ្ញត្តិដែលចាំបាច់ខានមិនបាន និងដែលចែងច្បាស់លាស់នៃវិធាន៧២(ក)ដែលទាក់ទងទៅនឹងសម្រេចបញ្ចប់នៃញត្តិបឋមនានានៅមុនពេលចាប់ផ្ដើមនៃសវនាការជំនុំជម្រះក្ដី តែមិនបានជឿតាមថាកំហុសដែលធ្វើឱ្យមោឃៈដល់សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ ដែលហេតុនេះក៏បានបដិសេធចោលនូវការលើកសំអាងនានារបស់ដើមបណ្ដឹងសាទុក្ខ[43]។ អាស្រ័យហេតុនេះ ដើម្បីឱ្យបំពេញបានទៅតាមបទដ្ឋាននៃការពិនិត្យឡើងវិញជាធរមានកំហុសនានាខាងអង្គច្បាប់នោះ សហព្រះរាជអាជ្ញាលើកឡើងថា ដើមបណ្ដឹងសាទុក្ខមិនគ្រាន់តែត្រូវកំណត់ឱ្យបានជាក់លាក់អំពីកំហុសនានាដែលត្រូវបានចោទប្រកាន់ប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវបង្ហាញដោយផ្អែកលើការថ្លឹងថ្លែងអំពីភវនីយភាពដើម្បីឱ្យឃើញផងដែរថា តើកំហុសនោះធ្វើឱ្យមោឃៈដល់សេចក្ដីសម្រេចដែលកំពុងតវ៉ាបែបដូចម្ដេចខ្លះ?។

### ii. *អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសខាងអង្គច្បាប់ដូចធ្វើឱ្យមោឃៈដល់សេចក្ដីសម្រេចដែលកំពុងតវ៉ានោះឡើយ*

២២- មេធាវីការពារក្ដីរបស់ នួន ជា បានចោទប្រកាន់អំពីកំហុសខាងអង្គច្បាប់ចំនួនបីនៅក្នុងសេចក្ដីសំរេចដែលកំពុងមានបញ្ហា៖ ទឡ្ហីករណ៍ទីមួយ ទីពីរនិងទីបីមានលើកឡើងនៅក្នុងកថាខណ្ឌទី៣ខាងលើស្រាប់ហើយ។ សហព្រះរាជអាជ្ញា បានលើកយោបល់ប្រកែកតវ៉ានៅក្នុងកថាខណ្ឌទី១១និងទី១៦ខាងលើហើយថា ទឡ្ហីករណ៍ទីមួយ និងទីបីក្នុងការធ្វើបណ្ដឹងសាទុក្ខមិនអាចទទួលយកបានឡើយនៅចំពោះមុខអង្គជំនុំជម្រះ។ បើសិនជា អង្គជំនុំជម្រះរកឃើញថា ទឡ្ហីករណ៍ណាមួយឬទាំងបីនៃការធ្វើបណ្ដឹងសាទុក្ខអាចទទួលយកបាននោះ សហព្រះរាជអាជ្ញាសូមលើកជាមតិថា នៅក្នុងករណីនីមួយៗ អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសខាងអង្គហេតុ ដូចជាធ្វើឱ្យមោឃៈដល់សេចក្ដីសម្រេចដែលកំពុងតវ៉ានោះឡើយ។

[43] *ដូចគ្នានឹងខាងលើ។*

<u>ទទ្បីករណ៍ទីមួយនៃការធ្វើបណ្តឹងសាទុក្ខមិនមានមូលដ្ឋានត្រឹមត្រូវទាល់តែសោះ</u>

២៣- នៅក្នុងទទ្បីករណ៍ទីមួយនៃការធ្វើបណ្តឹងសាទុក្ខរបស់ខ្លួន មេធាវីការពារក្តីបានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងបានមានកំហុសខាងអង្គហេតុ ដោយមិនបានផ្តល់មូលហេតុដើម្បីបញ្ជាក់អំពីការខកខានដែលបានពោលអះអាងស្តីពីការដែល អជសដ មិនបានពិនិត្យពិចារណាលើបណ្តឹងនានារបស់មេធាវីដែលស្តីពីការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងសំណុំរឿងលេខ០០២ នោះឡើយ។

២៤- ច្បាប់ជាធរមាននៅក្នុងសេចក្តីសម្រេចនានា ដែលមានបញ្ជាក់មូលហេតុបានបង្ហាញសក្ខីកម្មយ៉ាងច្បាស់ថា ស្ថាប័ននានារបស់តុលាការមានភារកិច្ចត្រូវផ្តល់នូវសេចក្តីសម្រេចដោយមានបញ្ជាក់មូលហេតុ ដែលជាគោលការណ៍មួយដែលកើតចេញមកពីកាតព្វកិច្ចនានាខាងសិទ្ធិមនុស្សដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងអន្តរជាតិនានា ក៏ដូចជាយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិនានា។ ច្បាប់លក្ខន្តិកៈដែលគ្រប់គ្រងលើតុលាការ ICC, ICTY, និង ICTR គឺមានភាពឯកឆន្ទក្នុងការតម្រូវឲ្យមានការផ្តល់យោបល់បញ្ជាក់ពីមូលហេតុជាលាយលក្ខណ៍អក្សរនៅក្នុងសេចក្តីសម្រេចនានារបស់តុលាការ[44]។ លើសពីនេះទៅទៀត សេចក្តីសម្រេចដោយមានបញ្ជាក់មូលហេតុណាមួយរបស់អង្គជំនុំជម្រះសាលាដំបូង នឹងជួយធានានាដល់គោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាននានាដែលទាក់ទងនឹងសិទ្ធិរបស់ចុងចោទនៅក្នុងករណីរឿងក្តីព្រហ្មទណ្ឌដើម្បីឲ្យទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវ និងសិទ្ធិក្នុងការប្តឹងសាទុក្ខ[45]។

---

[44] សូមអាន លក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី, សេចក្តីសម្រេចចិត្តលេខ S.C. Res 827, មាត្រា២៣ (ឆ្នាំ១៩៩៣)។ លក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា, សេចក្តីសម្រេចចិត្តលេខ S.C. Res. 955, មាត្រា២២ (ឆ្នាំ១៩៩៤)។ លក្ខន្តិកៈទីក្រុងរ៉ូម របស់តុលាការ ICC, ដែលត្រូវបានអនុម័តដោយ សន្និសីទអ្នកការទូតនៃ អសប (U.N. Diplomatic Conference), មាត្រា៧៤ (ចុះថ្ងៃទី១៧ កក្កដា ១៩៩៨)។

[45] កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ, មាត្រា១៤, ឯកសារលេខ 999 U.N.T.S. 171 (ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៩៦)។ សូមអានផងដែរ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Momir Nikolić,* សំណុំរឿងលេខ IT-02-60/1-A, សាលដីកាសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការសម្រេចផ្តន្ទាទោស (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី៨ មីនា២០០៦ ត្រង់កថាខណ្ឌទី ៩៦។ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Dragoljub Kunarac*, និងគូរកន, សំណុំរឿងលេខ IT-96-23 និងលេខ IT-96-23/1-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី១២ មិថុនា ២០០២។

២៥- អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានបង្ហាញភ័ស្តុតាងថា លក្ខខណ្ឌបានតម្រូវឱ្យមានដែនកំណត់នៃការគោរពតាម ចំពោះការរកឃើញខាងអង្គហេតុនានារបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងពេលត្រូវធ្វើការវាយតម្លៃអំពីថា តើសេចក្តីសម្រេចណាមួយមានផ្តល់ការបញ្ជាក់មូលហេតុបានត្រឹមត្រូវដែរ ឬទេ?៖

> *ភារកិច្ចនៃការធ្វើសវនាការ ការវាយតម្លៃ និងការថ្លឹងថ្លែងនូវភ័ស្តុតាងដែលបានបង្ហាញជូននៅក្នុងសវនាការជំនុំជម្រះក្តី ជាសំខាន់គឺត្រូវទុកឱ្យអង្គជំនុំជម្រះសាលាដំបូង។ ហេតុដូចនេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ត្រូវតែផ្តល់ដែនកំណត់នៃការគោពតាមដល់ការរកឃើញខាងអង្គហេតុដែលសម្រេចបានដោយអង្គជំនុំជម្រះសាលាដំបូង[នៅក្នុងពេលធ្វើការវាយតម្លៃលើសេចក្តីសម្រេចដោយមាការបញ្ជាក់មូលហេតុរបស់អង្គជំនុំជម្រះនេះ]* [46] ។

"អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចទូទៅមួយ ក្នុងការដាក់ចេញនូវយោបល់ដោយមានការបញ្ជាក់មូលហេតុ"[47]ដែលមានផ្តល់នូវការវែកញែកហេតុផលគ្រប់គ្រាន់សម្រាប់ការវាយតម្លៃរបស់ខ្លួននិង"ត្រូវធ្វើការថ្លឹងថ្លែងឱ្យបានគ្រប់ជ្រុងជ្រោយជាមួយនឹងរាល់កត្តាទាំងអស់ដែលពាក់ព័ន្ធ"[48]។ ប៉ុន្តែ "កម្រិតនៃការវែកញែកហេតុផលរបស់[អង្គជំនុំជម្រះ] គឺវាអាស្រ័យទៅលើកាលៈទេសៈនៃករណីរឿង"[49]។ លើសពីនេះ ដោយសារអង្គជំនុំជម្រះសាលាដំបូងត្រូវមានកាតព្វកិច្ចក្នុងការ

---

[46] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Dragoljub Kunarac*, និងគូរកន, សំណុំរឿងលេខ IT-96-23 និងលេខ IT-96-23/1-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី១២ មិថុនា ២០០២ ត្រង់កថាខណ្ឌទី៣៩។

[47] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Momir Nikolić*, សំណុំរឿងលេខ IT-02-60/1-A, សាលដីកាសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការសម្រេចផ្តន្ទាទោស (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី៨ មីនា២០០៦ ត្រង់កថាខណ្ឌទី ៩៦។

[48] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Dragoljub Kunarac*, និងគូរកន, សំណុំរឿងលេខ IT-96-23 និងលេខ IT-96-23/1-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី១២ មិថុនា ២០០២ ត្រង់កថាខណ្ឌទី៣២៤។

[49] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo*, សំណុំរឿងលេខ ICC-01/04-01/06 (OA 5), សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទី I ដែលមានចំណងជើងថា " សេចក្តីសម្រេចលើកទីមួយលើសំណើរបស់អយ្យការ និងសំណើដែលត្រូវបានកែប្រែសម្រាប់ការកោសលុបចេញមួយចំនួនអនុលោមតាមវិធាន៨១" (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICC), ចុះថ្ងៃទី១៤ ធ្នូ ២០០៦ ត្រង់កថាខណ្ឌទី២០។

បញ្ជាក់ពីមូលហេតុនៃការធ្វើសេចក្តីរបស់ខ្លួននោះ គឺមិនតម្រូវឱ្យនិយាយបញ្ជាក់អំពីការវែកញែកហេតុផលដោយលំអិតនោះឡើយ[50]។

២៦- អាស្រ័យហេតុនេះ ជាការចាំបាច់ដើមបណ្តឹងសាទុក្ខណាម្នាក់លើកឡើងអះអាងអំពីកំហុសខាងអង្គច្បាប់ដោយសារការខ្វះការផ្តល់យោបល់បញ្ជាក់ពីមូលហេតុដើម្បីកំណត់អត្តសញ្ញាណអំពី "បញ្ហាជាក់លាក់នានា, អំពីការរកឃើញខាងអង្គហេតុ ឬអំពីការលើកសំអាងផ្សេងៗដែលដើមបណ្តឹងសាទុក្ខដាក់ជូនទៅអង្គជំនុំជម្រះសាលាដំបូងដោយភ្លេចមិនបានលើកឡើងនិងមិនបានពន្យល់អំពីថា តើហេតុអ្វីបានជាការភ្លេចភ្លាំងនេះធ្វើឱ្យមោឃៈដល់សេចក្តីសម្រេច?"[51]។

២៧- ទាក់ទងអំពីកម្រិតនៃការផ្តល់នូវការបញ្ជាក់មូលហេតុ ដែលរំពឹងចង់បានពីអង្គជំនុំជម្រះសាលាដំបូងនោះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICC បានសម្រេចថា ការវែកញែកហេតុផលគ្រប់គ្រាន់"គឺមិនចាំបាច់តម្រូវឱ្យរៀបរាប់ពីកត្តានីមួយៗ និងគ្រប់រាល់កត្តាទាំងអស់ដែលស្ថិតនៅចំពោះមុខ [អង្គជំនុំជម្រះ] ដើម្បីដាក់ចេញមួយៗដោយឡែកពីគ្នានោះទេ ប៉ុន្តែគោងតែបញ្ជាក់អត្តសញ្ញាណឱ្យបានច្បាស់ថា តើអង្គហេតុណាមួយដែលត្រូវបានរកឃើញពាក់ព័ន្ធគ្នាជាមួយនឹងការឈានទៅរកការធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន"[52]។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR តម្រូវឱ្យ "អង្គជំនុំជម្រះសាលាដំបូងត្រូវតែផ្តល់ជាអប្បបរមានូវការបញ្ជាក់មូលហេតុដែលគាំទ្រការរកឃើញរបស់ខ្លួន ស្តីពីការពិចារណាដ៏មានសារៈសំខាន់ ដែលទាក់ទងនឹងការធ្វើសេចក្តី

---

[50] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Radovan Karadžić*, សំណុំរឿងលេខ IT-95-5/18-AR73.5, សាលដីកាសម្រេចលើបណ្តឹងសាទុក្ខរបស់ Radovan Karadžić អំពីសេចក្តីសម្រេចស្តីពីការចាប់ផ្តើមសវនាការជំនុំជម្រះក្តី (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី១៣ តុលា ២០០៩ ត្រង់កថាខណ្ឌទី២០។ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* Slobodan Milošević, សំណុំរឿងលេខ IT-02-54-AR73.6, សាលដីកាសម្រេចលើបណ្តឹងសាទុក្ខលើបញ្ហាបន្ទាន់បង្ខំដោយអ្នកដែលមិនមែនជាគូភាគីនៅក្នុងរឿងក្តី ប្រឆាំងនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការបង្ហាញ និងការត្រៀមរៀបចំសារណាការពារក្តី (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី២០ មករា ២០០៤ ត្រង់កថាខណ្ឌទី៧។

[51] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Miroslav Kvočka* និងគូរកន, សំណុំរឿងលេខ IT-98-30/1-A, សាលដីកាលើបណ្តឹងសាទុក្ខ (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី២៨ កុម្ភៈ ២០០៥ ត្រង់កថាខណ្ឌទី៣៦៨។

[52] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo*, សំណុំរឿងលេខ ICC-01/04-01/06 (OA 5), សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទី I ដែលមានចំណងជើងថា " សេចក្តីសម្រេចលើកទីមួយលើសំណើរបស់អយ្យការ និងសំណើដែលត្រូវបានកែប្រែសម្រាប់ការកោសលុបចេញមួយចំនួនអនុលោមតាមវិធាន៨១" (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICC), ចុះថ្ងៃទី១៤ ធ្នូ ២០០៦ ត្រង់កថាខណ្ឌទី២០(សង្កត់ន័យបន្ថែមដោយអក្សរទ្រេត)។

សម្រេចរបស់ខ្លួន”[53]។ ទំហំនៃការលើកសំអាងជាលាយលក្ខណ៍អក្សររបស់អង្គជំនុំជម្រះសាលាដំបូង នឹងមិនមានការជាប់ទាក់ទងគ្នាទេ ដរាបណាអង្គជំនុំជម្រះនេះបានផ្តល់នូវការវែកញែកហេតុផលដែល អាចឲ្យជឿបាន[54]។

២៨- ដូចដែលបានលើកឡើងនៅក្នុងកថាខណ្ឌទី១១ខាងលើស្រាប់ សេចក្តីសម្រេចដែលកំពុងតវ៉ាបាន សម្រេចបញ្ចប់(disposes)នូវការពោលអះអាង(claims)ជាក់លាក់ចំនួនពីរ របស់របស់មេធាវីការពារ ក្តីអំពីការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលកម្ពុជា (RGC) នៅក្នុងសំណុំរឿងលេខ០០២ ដោយយោង ទៅលើអញ្ញត្តកម្មបឋម ដែលនៅក្នុងនោះការពោលអះអាងទាំងនេះត្រូវបានលើកឡើងកាលពីដើម ដំបូង- ហើយគឺមិនមែននៅក្នុងសំណើសុំលើកទីមួយ ដែលការអះអាងដូចគ្នានេះត្រូវបានលើកឡើង ដដែលៗនោះទេ។ អង្គជំនុំជម្រះសាលាដំបូងលើកឡើងអំពីកថាខណ្ឌពីរនៃអត្ថបទដែលមានការបញ្ជាក់ មូលហេតុនៅក្នុងនោះដើម្បីធ្វើយុត្តិកម្មចំពោះសេចក្តីសម្រេចនេះ[55]។ អង្គជំនុំជម្រះសាលាដំបូងបាន អនុវត្តដោយត្រឹមត្រូវនូវឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីជាផលប្រយោជន៍ដល់ការសន្សំសំចៃថវិកានិងប្រសិទ្ធ ភាពមិនមែនដើម្បីសម្រេចបញ្ចប់សារជាថ្មីម្តងទៀត(re-dispose) លើការពោលអះអាងដដែលៗនៅ ក្នុងពេលធ្វើការវាយតម្លៃលើសំណើសុំទីមួយនោះឡើយ។ សហព្រះរាជអាជ្ញា សូមជូនជាមតិថា វិសាលភាពនៃការវែកញែកហេតុផលនេះ គឺជាការបំពេញបានទៅតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់នៃ ចំណុចចាប់ផ្តើម ដើម្បីឲ្យសេចក្តីសម្រេចមានការបញ្ជាក់ហេតុផលបានត្រឹមត្រូវដូចដែលបានលើក ឡើងខាងលើ។

## <u>ទទ្បីករណ៍ទីពីរនៃបណ្តឹងសាទុក្ខមិនមានមូលដ្ឋានត្រឹមត្រូវទេ</u>

២៩- នៅក្នុងទទ្បីករណ៍ទីពីរនៃបណ្តឹងសាទុក្ខរបស់ខ្លួន មេធាវីការពារក្តីលើកឡើងចោទប្រកាន់ ថា អង្គជំនុំ ជម្រះសាលាដំបូងបានមានកំហុសខាងអង្គច្បាប់តាមរយៈ “ការខកខាន” មួយឈុតដែល តម្រូវឲ្យ

---

[53] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Édouard Karemera*, សំណុំរឿងលេខ ICTR-98-44-AR73.1, សាលដីកាលើបណ្តឹងសាទុក្ខរបស់ Mathieu Ngirumpatse អំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី១៧ កញ្ញា ២០០៨ (អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃតុលាការ ICTR), ចុះថ្ងៃទី៣០ មករា ២០០៩ ត្រង់កថាខណ្ឌទី១៩។

[54] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Dragoljub Kunarac*, និងគូរកន, សំណុំរឿងលេខ IT-96-23 និងលេខ IT-96-23/1-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី១២ មិថុនា ២០០២ ត្រង់កថាខណ្ឌទី៣២៤។

[55] ឯកសារលេខ **E116** សេចក្តីសម្រេចដែលកំពុងតវ៉ា កំណត់សម្គាល់លេខ១ *ខាងលើ* កថាខណ្ឌទី១៥-១៦។

មានវិធានណាមួយក៏ដោយតាមវិធាន៣៥ ដែលបានភ្ជាប់ទៅនឹងបញ្ហាអង្គហេតុនានា ដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលដំណាលគ្នា, ដោយឡែកតាមរយៈការតម្រូវឲ្យការលើកឡើងចោទប្រកាន់ទាំងនោះត្រូវមាន "ផលប៉ះពាល់ជាក់ស្តែង" ទៅលើភាពយុត្តិធម៌នៃដំណើរការនីតិវិធីជំនុំជម្រះក្តីក្នុងសំណុំរឿង០០២[56]។ ទោះបីជាមេធាវីការពារក្តីលើកឡើងចោទប្រកាន់ថា អង្គជំនុំ ជម្រះសាលាដំបូងបន្ថែមនូវលក្ខខណ្ឌតម្រូវដ៏ខុសឆ្គងមួយថែមទៀត ស្តីពី"ព្យសនកម្មជាក់ស្តែង"[57]ក៏ដោយក៏ សហព្រះរាជអាជ្ញាមិនអាចរកឃើញនូវសេចក្តីយោងណាមួយ ទៅលើលក្ខខណ្ឌតម្រូវបែបនោះនៅក្នុងផ្នែកពាក់ព័ន្ធនៃសេចក្តីសម្រេចដែលកំពុងតវ៉ានោះឡើយ ។

៣០- សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា វិធាន៣៥ បង្កើតនូវយុត្តាធិការបន្ទាប់បន្សំមួយសម្រាប់ស្ថាប័ននានារបស់តុលាការនៃ អវតក នៅក្នុងដំណាក់កាលផ្សេងៗនៃដំណើរការនីតិវិធី ដើម្បីត្រួតពិនិត្យលើសុចរិតភាពនៃដំណើរការនីនីតិវិធីតាមផ្លូវតុលាការ។ យុត្តាធិការបន្ទាប់បន្សំនេះ តាមរយៈការជំពាក់ជំពិនជាចាំបាច់នោះ ស្ថិតនៅលើមូលដ្ឋានស្របច្បាប់មួយដែលមានអត្ថិភាពពីមុនមកសម្រាប់យុត្តាធិការចម្បងនៃស្ថាប័នណាមួយរបស់តុលាការ មិនថានៅសាលាដំបូង ឬនៅសាលាឧទ្ធរណ៍នោះឡើយ។ ដោយការធ្វើការសម្រេចនៅលើសំណើនានាដែលដាក់ដោយ មេធាវីការពារក្តីនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ អង្គបុរេជំនុំជម្រះបានរកឃើញថា អំណាចដែលគេបានផ្តល់ឲ្យទៅសចស ឬ អង្គជំនុំជម្រះណាមួយដោយវិធាន៣៥ គឺជាកិច្ចប្រឹង ប្រែងមួយដើម្បីរក្សាការពារនូវកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អវតក ឲ្យចាកផុតពីចំណាត់ការមិន ត្រឹមត្រូវដែលអាចមានលើកឡើងជាសំណួរស្តីពីភាពត្រឹមត្រូវនៃដំណើរការនីតិវិធី[58]។ វិធាន៣៥ "មិនបានបង្កើតនូវយុត្តាធិការចំបងបន្ថែមណាមួយសម្រាប់ អវតក ឡើយ នេះជាការច្បាស់ណាស់ថា គឺហួសពីវិសាលភាពរបស់វិធាននេះ[59] ។

[56] សូមមើល **E116** សេចក្តីសម្រេចដែលកំពុងតវ៉ា, កំណត់សម្គាល់*ខាងលើ* លេខ១ ត្រង់កថាខណ្ឌទី ២១ ។ សូមមើល **E116/1/1** បណ្តឹងសាទុក្ខ, កំណត់សម្គាល់*ខាងលើ* លេខ៤ ត្រង់កថាខណ្ឌទី ២៥-៣១ ។

[57] **E116/1/1** បណ្តឹងសាទុក្ខ, កំណត់សម្គាល់*ខាងលើ* លេខ៤ ត្រង់កថាខណ្ឌទី ៣០ ។

[58] សូមមើល **D158/5/4/14** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើបំពេញកិច្ចស៊ើបសួរលើកទីដប់មួយរបស់ នួន ជា, ថ្ងៃទី២៥ សីហា ២០០៩ ត្រង់កថាខណ្ឌទី ៣០ ។

[59] **D158/5/4/14** *ដដែលដូចមុន* ។

៣១- លក្ខខណ្ឌតម្រូវជាចំណុចចាប់ផ្ដើមដែលការលើកឡើងចោទប្រកាន់ស្ដីពីការជ្រៀតជ្រែក ក្នុងកិច្ចការរដ្ឋបាលតុលាការ (i) ត្រូវតែភ្ជាប់គ្នាទៅនឹងបញ្ហាអង្គហេតុដែលបច្ចុប្បន្នកំពុងស្ថិតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និង (ii) ត្រូវមានផលប៉ះពាល់ជាក់ស្ដែងទៅលើភាពត្រឹមត្រូវនៃដំណើរការនីតិវិធីដែលអាចបង្ហាញឱ្យឃើញថា មានភាពស្របគ្នាជាមួយនឹងពាក្យពេចន៍ដែលចែងក្នុងវិធាន៣៥ ហើយគោលបំណងនៃវិធាននោះត្រូវតែដើម្បីរក្សាការពារនូវភាពត្រឹមត្រូវ ដូចដែលបានចែងបញ្ជាក់យ៉ាងច្បាស់នៅក្នុងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ។ បណ្ដឹងសាទុក្ខនេះ មិនបានចង្អុលភស្តុតាងលើកំហុសខាងអង្គច្បាប់ណាមួយអំពីបញ្ហានេះទេ ហើយក៏មិនបានបង្ហាញពីកំហុសដែលគេបានអះអាងនោះតើវាធ្វើឱ្យសេចក្ដីសម្រេចដែលកំពុងតវ៉ានេះអស់សុពលភាពបែបដូចម្ដេចនោះឡើយ។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមជូនសេចក្ដីសន្និដ្ឋានថា ទឡ្ហីករណ៍ទីពីរនៃបណ្ដឹងសាទុក្ខនេះមិនមានមូលដ្ឋានត្រឹមត្រូវទេ ហើយដែលអង្គជំនុំជម្រះសាលាដំបូងគួរតែបដិសេធចោល។

<u>ទឡ្ហីករណ៍ទីបីនៃបណ្ដឹងសាទុក្ខមិនមានមូលដ្ឋានទេ</u>

៣២- នៅក្នុងទឡ្ហីករណ៍ទីបីនៃបណ្ដឹងសាទុក្ខរបស់ខ្លួន មេធាវីការពារក្ដី នួន ជា លើកឡើងចោទប្រកាន់ ថាអង្គជំនុំជម្រះសាលាដំបូងបានមានកំហុសខាងអង្គច្បាប់នៅក្នុងការរកឃើញថា វិធាន៣៥ "មិនបានចែងការផ្ដួចផ្ដើមគំនិតបើកកិច្ចស៊ើបសួរតាមសំណើរបស់ភាគីណាមួយ"[60]។ ដូចដែលសហព្រះរាជអាជ្ញាបានផ្ដល់សំអាងនៅក្នុងកថាខណ្ឌទី១៤ និង ១៥ នៅខាងលើរួចហើយថា ទឡ្ហីករណ៍នៃបណ្ដឹងឧទ្ធរណ៍នេះបានពង្រីកឱ្យធំនូវសេចក្ដីសង្ខេបនៅក្នុងកំណត់សម្គាល់ជើងទំព័រ អំពីការរកឃើញខាងអង្គច្បាប់មួយរបស់អង្គបុរេជំនុំជម្រះ អំពីចំណុចប្រផុតប្រផើយមួយទាក់ទងនឹងស្ថានភាពនៃការរកឃើញខាងអង្គច្បាប់មួយរបស់អង្គជំនុំជម្រះសាលាដំបូង ដែលទោះជាមិនត្រឹមត្រូវ ឬដោយចេតនាក៏ដោយ ក៏ទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខនេះ មិនអាចទទួលយកបានទេ។

៣៣- ម្យ៉ាងវិញទៀត បើអង្គជំនុំជម្រះសាលាដំបូងត្រូវទទួលយកនូវទឡ្ហីករណ៍ទីបីនៃបណ្ដឹងសាទុក្ខនេះនោះ ផលវិបាកគឺគ្រាន់តែថា សេចក្ដីសម្រេចដែលកំពុងតវ៉ា នេះរួមបញ្ចូលនូវសេចក្ដីយោងមួយនៅក្នុងកំណត់សម្គាល់ជើងទំព័រទៅលើការរកឃើញខាងអង្គច្បាប់របស់អង្គបុរេជំនុំជម្រះ ដែលបន្ទាប់

---

[60] **E116/1/1** បណ្ដឹងសាទុក្ខ, កំណត់សម្គាល់*ខាងលើ* លេខ៤ ត្រង់កថាខណ្ឌទី ៣៥ ។

មកត្រូវបានពិនិត្យឡើងវិញ[61]ដោយអង្គជំនុំជម្រះ[62]។ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា គោលជំហរដែលបានពិនិត្យឡើងវិញរបស់អង្គបុរេជំនុំជម្រះនេះ មិនមានការជាប់ទាក់ទងដោយសមហេតុផលទៅនឹងចំណុចច្បាប់ដែលបានលើកឡើង នៅក្នុងសេចក្តីសម្រេចដែលកំពុងតវ៉ានោះឡើយ គឺថា"កិច្ចស៊ើបសួរណាមួយអនុលោមតាម [វិធាន៣៥] អាចនឹងដឹកនាំធ្វើប្រកបទៅដោយអត្ថន័យបាន លុះត្រាតែធ្វើដោយស្ថាប័នណាមួយរបស់តុលាការ ដែលត្រូវបានគេប្តឹងមកអំពីករណីនេះតែប៉ុណ្ណោះ"[63]។ ចំណុចច្បាប់នៅក្នុងសេចក្តីសម្រេចដែលកំពុងតវ៉ា នោះបានសំដៅទៅដល់បញ្ហាថា តើអង្គជំនុំជម្រះសាលាដំបូងមិនមែន សចស ឬអង្គបុរេជំនុំជម្រះទេ ដែលអាចចាត់ការអនុលោមតាមវិធាន៣៥ពាក់ព័ន្ធទៅនឹងសំណុំរឿងលេខ០០៣និង០០៤ ដែរឬទេ? ចំណុចច្បាប់ដែលក្រោយមកត្រូវបានពិនិត្យឡើងវិញដោយអង្គបុរេជំនុំជម្រះ គឺទាក់ទងនឹងគោលជំហររបស់ភាគីណាមួយនៅក្នុងការស្នើសុំឱ្យមានការផ្តួចផ្តើមគំនិតធ្វើការស៊ើបសួរអនុលោមតាមវិធាន៣៥។ នៅលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាអះអាងថា ទឡ្ហីករណ៍ទីបីនៃបណ្តឹងសាទុក្ខនេះ គឺមិនមានមូលដ្ឋានត្រឹមត្រូវទេ។ កំហុសអប្បបរមាអ្វីក៏ដោយដែលមាននៅក្នុងការយោងមិនត្រឹមត្រូវណាមួយទៅលើសេចក្តីសម្រេចដែលក្រោយមកត្រូវបានពិនិត្យឡើងវិញដោយសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនោះ គឺដើមបណ្តឹងសាទុក្ខបានខកខានមិនបានបង្ហាញឱ្យឃើញថា កំហុសបែបនេះបានធ្វើឱ្យមោឃៈដល់សេចក្តីសម្រេចដែលកំពុងតវ៉ាឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងគួរតែបដិសេធទឡ្ហីករណ៍ទីបីនៃបណ្តឹងសាទុក្ខនេះចោល។

### iii. *បទដ្ឋាននៃការពិនិត្យឡើងវិញតម្រូវឱ្យដើមបណ្តឹងសាទុក្ខធ្វើការបង្ហាញឱ្យឃើញថា កំហុសដែលបានលើកឡើងចោទប្រកាន់នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិ គឺមិនសមហេតុសមផលផង និងមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែតផងដែលបណ្តាលឱ្យមានការខូចខាតដល់សិទ្ធិរបស់ដើមបណ្តឹងសាទុក្ខ*

[61] **E116/1/1** បណ្តឹងសាទុក្ខ, *ដដែលដូចមុន* ។

[62] សាលដីកាពីររបស់អង្គបុរេជំនុំជម្រះ គឺ **D158/5/1/15** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើលើកទីដប់មួយរបស់ជនត្រូវចោទសុំបំពេញកិច្ចស៊ើបសួរ, ថ្ងៃទី១៨ សីហា ២០០៩ ត្រង់កថាខណ្ឌទី ២៩ និង **D314/2/7** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និង នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.សច.ស លើសំណើសុំឱ្យកោះហៅសាក្សី, ថ្ងៃទី៨ មិថុនា ២០១០ ត្រង់កថាខណ្ឌទី ៤៣ ។

[63] **E116** សេចក្តីសម្រេចដែលកំពុងតវ៉ា, កំណត់សម្គាល់លេខ១ *ខាងលើ* ត្រង់កថាខណ្ឌទី ២១ ។

៣៤- អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានវាយតម្លៃលើកត្តានានាដែលនឹងពាក់ព័ន្ធទៅនឹងការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខអំពីការអនុវត្តឆន្ទានុសិទ្ធិរបស់ចៅក្រមនៅឯតុលាការ៖

> *ហេតុដូចនេះ ដើមបណ្តឹងសាទុក្ខតោងតែបង្ហាញថាសេចក្តីសម្រេច[របស់] អង្គជំនុំជម្រះសាលាដំបូង* [...] *មានលក្ខណៈមិនសមហេតុសមផលខ្លាំងណាស់ ហើយមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែតតែម្តង ដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍អាចទាញជាសេចក្តីសន្និដ្ឋានបានថា ប្រាកដជាមានការខកខានមិនបានអនុវត្តឆន្ទានុសិទ្ធិដោយត្រឹមត្រូវ*[64] ។

៣៥- បទដ្ឋាននៃការពិនិត្យសារជាថ្មីឡើងវិញដោយអង្គបុរេជំនុំជម្រះនៅ អវតក គឺខ្ពស់ជាង ដោយតម្រូវឲ្យដើមបណ្តឹងសាទុក្ខធ្វើការបង្ហាញពី "ការរំលោភ" លើឆន្ទានុសិទ្ធិរបស់ចៅក្រមនៅលើទឡ្ហីករណ៍នានានៃភាពមិនត្រឹមត្រូវ ឬភាពមិនសមហេតុសមផល[65]។ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថាបទដ្ឋានដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានយកមកអនុវត្តដែល តម្រូវថា អង្គជំនុំជម្រះសាលាដំបូង "ខកខានមិនបានអុវត្តឆន្ទានិសិទ្ធិរបស់ខ្លួនឲ្យបានត្រឹមត្រូវ-" គឺ ស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹង "មានកំហុសដែលអាចឲ្យយល់ដឹងបាននៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង"ដែលតម្រូវដោយវិធាន១០៥ ហើយដែលអាចអនុវត្តបាននៅចំពោះមុខអង្គជំនុំជម្រះនេះ។ បទដ្ឋានរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ត្រូវបានបំពេញគ្រប់តែនៅក្នុងករណីដែលសេចក្តីសម្រេចដែលកំពុងតវ៉ានេះមានលក្ខណៈ"មិនសមហេតុផលខ្លាំងពេក និងមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែត"តែប៉ុណ្ណោះ ដូចជាអនុញ្ញាតឲ្យមានការជ្រៀតជ្រែកណាមួយហើយ

---

[64] *រដ្ឋអាជ្ញា ទល់នឹង Zdravko Tolimir* និងគូកន, សំណុំរឿងលេខ IT-04-80-AR65.1, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្គ្រប់ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលអនុញ្ញាតឲ្យមានការដោះលែងបណ្តោះអាសន្ន, ថ្ងៃទី១៩ តុលា ២០០៥ (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY) ត្រង់កថាខណ្ឌទី ៤ ។

[65] **D164/4/13** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម, ថ្ងៃទី១៨ វិច្ឆិកា ២០០៩, ERN 00402746-62 ត្រង់កថាខណ្ឌទី ២២-២៧ (លើកសំអាងទៅលើករណីរឿងរបស់ *Slobodan Milošević ទល់នឹង រដ្ឋអាជ្ញា,* សំណុំរឿងលេខ IT-02-54-AR73.7, សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គ្រប់ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការចាត់តាំងក្រុមមេធាវីការពារក្តី (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ថ្ងៃទី១ វិច្ឆិកា ២០០៤ ត្រង់កថាខណ្ឌទី ៩-១០) ។ **D140/9/5** សាលដីកាលើ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.សច.ស ដែលបដិសេធសំណើរបស់គាត់សុំតែងតាំងអ្នកជំនាញបន្ថែមមួយរូប ដើម្បីធ្វើការពិនិត្យឡើងវិញទៅលើខ្លឹមសារនៃរបាយការណ៍របស់អ្នកជំនាញ ដែលបានដាក់ជូនដោយលោកស្រី Ewa Tabeau និងលោក ថឺ ឃាម, ថ្ងៃទី២៨ មិថុនា ២០១០, ត្រង់កថាខណ្ឌទី ១៥-១៧ ។ **D356/2/9** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធលើសំណើ សុំយោបល់ពីអ្នកជំនាញ ជាលើកទីពីរ, ថ្ងៃទី១ កក្កដា ២០១០, ត្រង់កថាខណ្ឌទី ១៦-១៨ ។

អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឲ្យបានត្រឹមត្រូវ។ ភាសាដ៏មានគុណវុឌ្ឍិនេះអាចត្រូវបានចាត់ទុកថាមានភាពមិនសមហេតុសមផលទាំងស្រុង និងមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែត(ឬយ៉ាងជាក់ស្តែង)នៅមុនពេលអនុវត្តឆន្ទានុសិទ្ធិរបស់តុលាការ ដោយអង្គជំនុំជម្រះសាលាដំបូង ត្រូវបានទុកដោយឡែកជាបណ្តឹងសាទុក្ខនេះ។ សហព្រះរាជអាជ្ញាសូមជូនជាមតិថា អង្គជំនុំជម្រះគួរតែអនុវត្តបទដ្ឋានមួយស្រដៀងគ្នានេះ នៅក្នុងកិច្ចដំណើរការនីតិវិធី។

iv. *អង្គជំនុំជម្រះសាលាដំបូងមិនបានមានកំហុសដែលអាចឲ្យយល់ដឹងបានក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដែលបណ្តាលឲ្យមានការខូចខាតដល់សិទ្ធិរបស់ដើមបណ្តឹងសាទុក្ខនោះទេ*

៣៦- មេធាវីការពារក្តី នួន ជា បានលើកឡើងចោទប្រកាន់ពីកំហុសដែលអាចឲ្យយល់ដឹងបាន នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិដោយអង្គជំនុំជម្រះសាលាដំបូង៖ទឡ្ហីករណ៍ទីបួនដែលបានសរសេរនៅក្នុងកថាខណ្ឌទី៣ខាងលើ។ មេធាវីការពារក្តីបានលើកឡើងចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមិនបានកំណត់ឲ្យនូវ "តម្លៃជាភស្តុតាងសមហេតុដ៏ត្រឹមត្រូវ - proper probative value" ចំពោះការលើកឡើងចោទប្រកាន់ពីការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងសំណុំរឿងលេខ០០៣ និង០០៤ទេ ខណៈដែលធ្វើការវាយតម្លៃលើការអះអាងនានាអំពីការស៊ើបសួរក្នុងសំណុំរឿងលេខ០០២។ ពាក់ព័ន្ធនឹងទឡ្ហីករណ៍ដូចគ្នានៃបណ្តឹងសាទុក្ខ មេធាវីការពារក្តីលើកឡើងថា ការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូង "ដែលហាក់ដូចជាមានបំណងចង់គេចវេះ"[66]ដោយស្វែងរកធ្វើការចៀសវាងនូវការរកឃើញ"ដែលមិនអាចគេចរួច"[67]មួយ *ដោយគ្រាន់តែឃើញមួយក្រឡេកផ្នែកដំបូង* នូវការជ្រៀតជ្រែកពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ដោយការពុំបានកំណត់អំពីលក្ខណៈនៃឯកសារនានាដែលពាក់ព័ន្ធនឹងសំណុំរឿងលេខ០០៣ និង០០៤ ដែលជាប់ទាក់ទងទៅនឹងសេចក្តីសំអាងដែលបានឆ្លើយដោយជាក់លាក់តបទៅនឹងការពោលអះអាងនៅក្នុងសំណុំរឿងលេខ០០២ដែលថា "មានជាប់ទាក់ទងទៅនឹងការបញ្ជាក់បំភ្លឺអំពីបរិបទដែលមានភាពលប់លើគេ និងការបង្ហាញឲ្យឃើញពីទស្សនៈយល់ឃើញរបស់រាជរដ្ឋាភិបាលកម្ពុជា"[68]។

---

[66] **E116/1/1** បណ្តឹងសាទុក្ខ, កំណត់សម្គាល់ *ខាងលើ* លេខ៤ ត្រង់កថាខណ្ឌទី ៣៣ ។

[67] **E116/1/1** បណ្តឹងសាទុក្ខ, *ដដែលដូចមុន* ។

[68] **E116/1/1** បណ្តឹងសាទុក្ខ, *ដដែលដូចមុន* ។

៣៧- ដូច្នេះបញ្ហាជាបន្ទាប់មកទៀត នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះគឺ ថាតើការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះមានលក្ខណៈមិនសមហេតុផលខ្លាំងពេក ឬមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែត រហូតទាល់តែបណ្ដាលឲ្យមានកំហុសនៅក្នុងការអនុវត្តឆន្ទានុសិទ្ធិនោះ។ សហព្រះរាជអាជ្ញាសូមជូន សេចក្ដីសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនបានយ៉ាងត្រឹមត្រូវទាក់ទងនឹងការអះអាងរបស់មេធាវីការពារក្ដីដែលពាក់ព័ន្ធនេះ។ ក្នុងឋានៈជាស្ថាប័នរបស់តុលាការមួយដែលឯករាជ្យ វាគឺជាអង្គជំនុំជម្រះសាលាដំបូងនេះឯងហើយដែលត្រូវបានគេដាក់ឲ្យចំកន្លែងដ៏ល្អបំផុត ដើម្បីកំណត់ពីចរឹតលក្ខណៈនិងវិសាលភាពនៃភ័ស្តុតាងដែលបានតម្រូវឲ្យអនុវត្តយ៉ាងត្រឹមត្រូវនូវការទទួលខុសត្រូវនានារបស់ខ្លួនតាមវិធាន៣៥។ ឆន្ទានុសិទ្ធិទាក់ទងនឹងកត្តាពាក់ព័ន្ធនានា ឬឯកសារជាភ័ស្តុតាងតម្រូវដោយអង្គភាពតុលាការមួយ ដើម្បីត្រួតពិនិត្យដំណើរការរបស់ខ្លួនផ្ទាល់ - ដែលជាគោលបំណងនៃគោលនយោបាយច្បាប់ដ៏ជាក់ស្តែងនៃវិធាន៣៥ - គួរតែទាក់ទាញបាននូវសេចក្ដីគោរពមួយដ៏លើសលុបអំពីការពិនិត្យឡើងវិញខាងឧទ្ធរណ៍។

៣៨. សេចក្ដីសម្រេចដែលកំពុងតវ៉ានេះអាចបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណា អំពីខ្លឹមសារនិងទឡ្ហីករណ៍ទាំងអស់នៅក្នុងសំណើលើកទីមួយមុន នឹងសម្រេចបញ្ចប់សំណើនោះ រួមទាំងការលើកឡើងចោទប្រកាន់ពាក់ព័ន្ធនឹងសំណុំរឿង ០០៣ និង ០០៤ ផង។ ដោយឡែកអង្គជំនុំជម្រះសាលាដំបូងបានសង្ខេបបញ្ជីរឿងនៃសំណើលើកទីមួយ[69] ហើយបានពិចារណាលើការលើកឡើងចោទប្រកាន់នៅក្នុងសំណើលើកទីមួយ ដើម្បីឆ្លុះបញ្ចាំងពីការលើកឡើងចោទប្រកាន់ទាំងនោះនៅក្នុងអញ្ញត្រកម្មរបស់មេធាវីការពារក្ដី[70]។ អញ្ញត្រកម្មខ្លួនឯង រួមមានកថាខណ្ឌពីរដែលបានលើកឡើងចោទប្រកាន់ពីការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ដោយបានលើកឡើងពីចំណុចនានា ដែលស្ទើរតែដូចគ្នាបេះបិទ ទៅនឹងសំណើលើកទីមួយ ដែលត្រូវបានដាក់ជូននៅពីរខែបន្ទាប់ពីសំណើលើកទីមួយ[71]។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូង ច្បាស់ជាបានដឹងពីខ្លឹមសារនៃការលើកឡើងចោទប្រកាន់របស់មេធាវី ការពារក្ដីដែលពាក់ព័ន្ធនឹងការជ្រៀតជ្រែកក្នុងសំណុំរឿង ០០៣ និង ០០៤ ខណៈពេលដែលឈាន ដល់របកគំហើញខាងផ្លូវច្បាប់ ដែលមាន

---

[69] **E116** សេចក្ដីសម្រេចដែលកំពុងតវ៉ា, កំណត់សម្គាល់*ខាងលើ* លេខ៤ ត្រង់កថាខណ្ឌទី ១០ ។

[70] **E116** សេចក្ដីសម្រេចដែលកំពុងតវ៉ា, *ដដែលដូចមុន* ។

[71] **E51/3** អញ្ញត្រកម្មរួមបញ្ចូលគ្នា, កំណត់សម្គាល់*ខាងលើ* លេខ២៥ ត្រង់កថាខណ្ឌទី ១០-១២ ។

សំអាងអំពីសំណើរបស់មេធាវីការពារក្តីមួយនេះ គឺថា៖ (i) ដំណោះស្រាយដ៏សមស្របនៅក្នុងកាលៈទេសៈនេះគឺ សចស និង អបជ អំពីបណ្តឹងសាទុក្ខ, និង (ii) ដែលថាមេធាវីការពារក្តីកំណត់អត្តសញ្ញាណពី “ផលប៉ះពាល់ជាក់ស្តែង” នៃការលើក ឡើងចោទប្រកាន់ពាក់ព័ន្ធនឹង សំណុំរឿង០០៣ និង ០០៤ ស្តីពីភាពត្រឹមត្រូវនៃការជំនុំជម្រះក្តីក្នុងសំណុំរឿង០០២[72]។ នៅលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តយ៉ាងត្រឹមត្រូវនូវឆន្ទានុសិទ្ធិរបស់ខ្លួន ទាក់ទងទៅនឹងអំណះអំណាង របស់មេធាវីការពារក្តី និង មិនមានបុរេវិនិច្ឆ័យ ចំពោះមេធាវីការពារក្តីត្រូវបានបង្ហាញ ដោយដើមបណ្តឹងសាទុក្ខឡើយ។ អាស្រ័យហេតុដូច្នេះ ទឡ្ហីករណ៍ទីបួននៃបណ្តឹងសាទុក្ខនេះខកខានមិនបាន ត្រូវទៅតាមបទដ្ឋាននៃការពិនិត្យសារជាថ្មីឡើងវិញជាធរមាននិងគួរតែត្រូវបានបដិសេធចោល។

## ៣. បណ្តឹងសាទុក្ខ ពឹងផ្អែកលើអង្គហេតុនានាដែលអង្គជំនុំជម្រះសាលាដំបូងមិនអាចមានបាន

៣៩- មេធាវីការពារក្តីបានយោងដល់ព្រឹត្តិការណ៍ សេចក្តីថ្លែងការណ៍ និង ឯកសារជាច្រើនដែលកើតមានឡើងក្រោយកាលបរិច្ឆេទនៃសេចក្តីសម្រេចដែលកំពុងតវ៉ានេះ - ហេតុដូច្នេះហើយវាមិនអាចមានបានចំពោះអង្គជំនុំជម្រះសាលាដំបូង ខណៈដែលចេញសេចក្តីសម្រេចដែលកំពុងតវ៉ានេះ- ដើម្បីធ្វើកថាខណ្ឌប្រាំស្តីពីការពោលអះអាងពីអង្គហេតុនៅពេលដើមដំបូងនៃបណ្តឹងសាទុក្ខ[73] និងដើម្បីធ្វើយុត្តិកម្មលើសំណើនានាតាមផ្លូវច្បាប់[74]។ ក្នុងការធ្វើដូច្នេះ មេធាវីការពារក្តីមិនបានអះអាងពឹងផ្អែកលើអំណាចរបស់អង្គជំនុំជម្រះដើម្បីពិនិត្យមើលភ័ស្តុតាងដោយខ្លួនឯងទេ[75] មិនបានធ្វើ សំណើតាមវិធាន១០៧.៧ ទេ, ហើយមិនបានចុះជាបញ្ជីនូវឯកសារបន្ថែមទាំងនេះដែលមិនមែនជា ប្រភពច្បាប់ដោយខ្លួននោះនៅក្នុងតារាងមួយ ឬច្រើន ឬមួយក៏មិនបានចុះជាឧបសម្ព័ន្ធនូវឯកសារទាំងនេះដូចដែលសេចក្តីណែនាំអនុវត្ត៦.៥ បានតម្រូវនោះឡើយ[76]។ សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានថា អង្គជំនុំជម្រះគួរតែកុំយកចិត្តទុកដាក់នឹងការអះអាងលើអង្គហេតុពាក់ព័ន្ធ នឹងព្រឹត្តិការណ៍ដែលកើតឡើងក្រោយ

---

[72] **E116** សេចក្តីសម្រេចដែលកំពុងតវ៉ា, កំណត់សម្គាល់*ខាងលើ* លេខ៤ ត្រង់កថាខណ្ឌទី ២១ ។

[73] សូមមើល, ឧទា. **E116/1/1** បណ្តឹងសាទុក្ខ, កំណត់សម្គាល់*ខាងលើ* លេខ៤ ត្រង់កថាខណ្ឌទី ៥-១០ ។

[74] សូមមើល, ឧទា. **E116/1/1** បណ្តឹងសាទុក្ខ, *ដដែលដូចមុន* ត្រង់កថាខណ្ឌទី ៣៨-៣៩ ។

[75] វិធាន ១០៤.១ នៃវិធានផ្ទៃក្នុង ។

[76] សេចក្តីណែនាំអនុវត្ត អវតក/២០០៧/១/វិសោធនកម្មលើកទី៧ ។

កាលបរិច្ឆេទ នៃដីកាសម្រេចដែលកំពុងតវ៉ា នៅពេលដែលអនុវត្តអំណាចរបស់ខ្លួនក្នុងការពិនិត្យសារជាថ្មីឡើងវិញខាងខទ្ទរណ៍នេះ។

## ៤. ដំណោះស្រាយស៊ើបសួរដែលបានស្នើសុំ គឺហួសផុតពីវិសាលភាពនៃវិធាន៣៥

៤០- មេធាវីការពារក្តីបានស្នើសុំដល់អង្គជំនុំជម្រះ *ដែលនៅក្នុងចំណោមបញ្ហាផ្សេងៗទៀត* *inter alia* បង្គាប់ឱ្យមាន "ការស៊ើបអង្កេតជាសាធារណៈ អនុលោមតាមវិធាន៣៥" ដែលនឹងត្រូវបានដឹកនាំអនុវត្ត ដោយអង្គភាពតុលាការមួយដែល "បានបង្ហាញពីភាពឯករាជ្យ" ដែលមិនរួមបញ្ចូលនូវបុគ្គលណាមួយដែលការប្រព្រឹត្តិរបស់គាត់ ដែលបានលើកឡើងចោទប្រកាន់នោះ បង្កើតបានជាមូលដ្ឋាននៃសំណើលើកទីមួយ ឬបណ្តឹងសាទុក្ខ។ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា វាមិនមានមូលដ្ឋានណាមួយតាមវិធាន៣៥ សម្រាប់ឱ្យអង្គជំនុំជម្រះ "បង្គាប់" ដល់អង្គភាពតុលាការខាងក្រៅឱ្យដឹកនាំធ្វើការស៊ើបសួរតាមវិធាន៣៥នោះឡើយ - គឺអង្គជំនុំជម្រះ ខ្លួនឯងនេះហើយ ដែលធ្វើការវាយតម្លៃថាតើត្រូវទៅតាមចំណុចចាប់ផ្តើមដំបូងនៃភ័ស្តុតាងហើយឬនៅ ("មានហេតុផលជឿថា បុគ្គលណាម្នាក់អាចធ្លាប់បានប្រព្រឹត្តិអំពើណាមួយនៅក្នុងចំណោមអំពើទាំងឡាយ ដែលបានចែងនៅក្នុងអនុវិធាន ១") ហើយបន្ទាប់មកអាចនឹងធ្វើការកំណត់ដើម្បី "បញ្ជូន" បញ្ហាណា មួយនោះទៅអាជ្ញាធរនៃព្រះរាជាណាចក្រកម្ពុជា ឬអង្គការសហប្រជាជាតិ - ដូចជាជម្រើសណាមួយក្នុងចំណោមជម្រើសទាំងបី[77]។

## ៥. យ៉ាងណាក៏ដោយ អង្គជំនុំជម្រះអាចចាត់ការ ***តាមឆន្ទៈរបស់ខ្លួនផ្ទាល់*** **(*proprio motu*)** ដើម្បីស៊ើបអង្កេត ពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ នៅក្នុងសំណុំរឿង ០០២

៤១- នៅពេលដែលបានទទួលបណ្តឹងសាទុក្ខនេះ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា អង្គជំនុំជម្រះមានសមត្ថកិច្ចបន្ទាប់បន្សំជាចាំបាច់ក្នុងការចាត់វិធានការសមស្របមួយចំនួន ដើម្បីលើកស្ទួយនិងគាំទ្រដល់ភាពសុចរឹតនៃដំណើរការនីតិវិធីស៊ើបសួរ។ សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានថា ការបកស្រាយពីវិសាលភាពនៃសមត្ថកិច្ចរបស់អង្គជំនុំជម្រះនេះ គឺមានភាពរលូនជាទីបំផុតជាមួយនឹងវិធាន ដោយមានការពិចារណាដោយឡែកពីអំណាចជាក់ស្តែងរបស់អង្គជំនុំជម្រះ ក្នុងការពិនិត្យ

[77] វិធាន ៣៥.២ នៃវិធានផ្ទៃក្នុង ។

មើលភ័ស្តុតាង និងការបង្គាប់ឲ្យដាក់ភ័ស្តុតាងថ្មី[78], ភាពផ្តាច់ព្រ័ត្រនៃបណ្តឹងសាទុក្ខនានានៅចំពោះមុខអង្គជំនុំជម្រះ[79] ហើយនិងអលទ្ធភាពនៃការបង្វិលសេចក្តីសម្រេចទៅឲ្យអង្គជំនុំជម្រះសាលាដំបូងវិញ[80]។

៤២- សហព្រះរាជអាជ្ញាបានសង្កេតឃើញថា នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១១ សារព័ត៌មាន ឌឹ ឃែមបូឌា ដេលី បានចេញផ្សាយអត្ថបទមួយ ("អត្ថបទសារព័ត៌មាន ឌឹ ឃែមបូឌា ដេលី") រាយការណ៍ពីបណ្តឹងសាទុក្ខហើយបានបោះផ្សាយជាថ្មីនូវផ្នែកនៃ*ពាក្យដូចគ្នាគ្រប់ម៉ាត់ (verbatim)* នៃបណ្តឹងសាទុក្ខ[81]។ ខ្លឹមសារនៃអត្ថបទសារព័ត៌មាន ឌឹ ឃែមបូឌា ដេលី បានផ្តល់នូវហេតុផល ដែលជឿបានថាបណ្តឹងសាទុក្ខសម្ងាត់នេះ ឬខ្លឹមសាររបស់វាត្រូវបានផ្សាយចេញទៅឲ្យម្ចាស់អត្ថបទនោះ។

៤៣- ទោះបីជាការដាក់ជូននានាទៅ អវតក ត្រូវមានដាក់ចំណាត់ថ្នាក់ឯកសារដែលបានស្នើក៏ដោយក៏អង្គជំនុំជម្រះអាចបង្គាប់ឲ្យដាក់ចំណាត់ថ្នាក់ផ្សេងមួយ អាស្រ័យលើការកំណត់ថាតើចំណាត់ថ្នាក់ដែលស្នើឡើងដោយភាគីដាក់ឯកសារត្រឹមត្រូវដែរឬទេ[82]។ ផ្ទុយទៅនឹងសំណើរបស់មេធាវីការពារក្តី និងអំណះអំណាងរបស់ខ្លួនដែលមានជាបញ្ហាដែលថា ដោយមិនគិតពីចំណាត់ថ្នាក់នៃបណ្តឹងសាទុក្ខនោះឡើយ "មេធាវីការពារក្តីនឹងចាត់ទុកវាជា" ឯកសារសាធារណៈ[83] អង្គជំនុំជម្រះបានចាត់ថ្នាក់បណ្តឹងសាទុក្ខជាឯកសារសម្ងាត់[84]។ ហេតុដូច្នេះ អង្គជំនុំជម្រះអាចត្រូវបានចាត់ទុកថាធ្លាប់បានបង្គាប់ថាបណ្តឹងសាទុក្ខនោះត្រូវបានចាត់ទុកថាជាឯកសារសម្ងាត់បណ្តោះអាសន្ន។ ដូច្នេះហើយ វាអាចត្រូវបានបើកចំហរដល់ បុគ្គលទាំងឡាយណាដែលបានចុះឈ្មោះជាបញ្ជីនៅក្នុង មាត្រា២.ឃ(ii)

[78] វិធាន ១០៥.១ នៃវិធានផ្ទៃក្នុង៖ "អង្គជំនុំជម្រះតុលាការកំពូលខ្លួនឯង អាចបើកការពិនិត្យលើភស្តុតាង និងស្វែងរកភស្តុតាងថ្មី ដើម្បីធ្វើការសម្រេចលើបញ្ហានេះ" ។

[79] វិធាន ១០៤.៣ នៃវិធានផ្ទៃក្នុង៖ "សេចក្តីសម្រេចនៃអង្គជំនុំជម្រះតុលាការកំពូល គឺជាសេចក្តីសម្រេចចុងក្រោយ..." ។

[80] វិធាន ១០៤.៣ នៃវិធានផ្ទៃក្នុង៖ "សេចក្តីសម្រេចនៃអង្គជំនុំជម្រះតុលាការកំពូល... មិនត្រូវបង្វិលឲ្យអង្គជំនុំជម្រះសាលាដំបូងវិញឡើយ" ។

[81] Julia Wallace និង Alice Foster, "ផលវិបាកបណ្តាលមកពីការលាលែងរបស់លោក Blunk នៅតែមានជាបន្ត -, សារព័ត៌មាន ឌឹ ឃែមបូឌា ដេលី (ភ្នំពេញ), ថ្ងៃទី១២ តុលា ២០១១ ត្រង់ទំព័រទី ១-២, ERN 00748643-00748643 បានដកស្រង់ពី **E116/1/1** បណ្តឹងសាទុក្ខ, កំណត់សម្គាល់*ខាងលើ* លេខ៤ ត្រង់កថាខណ្ឌទី ៣៧ និង ៣៨ (ឧបសម្ព័ន្ធ)។

[82] សេចក្តីណែនាំអនុវត្ត អវតក/០១/២០០៧/វិសោធនកម្មលើកទី៧៖ ការដាក់ឯកសារនៅចំពោះមុខ អវតក (វិសោធនកម្មលើកទី៧), ថ្ងៃទី១៧ សីហា ២០១១, មាត្រា ៣.១៣ ។

[83] **E116/1/1** បណ្តឹងសាទុក្ខ, កំណត់សម្គាល់*ខាងលើ* លេខ៤ ត្រង់កថាខណ្ឌទី ១, កំណត់សម្គាល់លេខ៤ ។

[84] **E116/1/1** បណ្តឹងសាទុក្ខ, កំណត់សម្គាល់*ខាងលើ* លេខ៤ (ទំព័រចំណងជើង) ។ ប្រៀបធៀប *ដដែលដូចមុន*, កថាខណ្ឌទី ១, កំណត់សម្គាល់លេខ៤ ។

នៃសេចក្តីណែនាំអនុវត្តស្តីពីការចាត់ថ្នាក់ឯកសារ តែប៉ុណ្ណោះ[85]។ ដូច្នេះ សហព្រះរាជអាជ្ញាបានសង្កេតឃើញថា បណ្តឹងសាទុក្ខ និងខ្លឹមសាររបស់វាទំនងជាមានលេចឡើងថា ត្រូវបានផ្សាយចេញឲ្យដល់អ្នកទទួល (ឯកសារ) ដែលមិនបានអនុញ្ញាតនោះ គឺជាការរំលោភលើដីការបស់អង្គជំនុំជម្រះ។

## III. សេចក្តីសន្និដ្ឋាន

៤៤- អាស្រ័យហេតុដូចខាងលើនេះ សហព្រះរាជអាជ្ញាសូមស្នើដោយគោរពដល់អង្គជំនុំជម្រះតុលាការកំពូលសូមឲ្យ៖

ក. រកឲ្យឃើញថា ទឡ្ហីករណ៍ទីមួយ និងទឡ្ហីករណ៍ទីបី នៃបណ្តឹងសាទុក្ខ មិនអាចទទួលយកបានទេ។

ខ. បដិសេធបណ្តឹងសាទុក្ខនេះទាំងមូល ដោយសារតែខកខានមិនបានបំពេញតាមបទដ្ឋាន ស្តីពីការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ។

គ. ចាត់វិធានការណាមួយក៏ដោយដែលអង្គជំនុំជម្រះយល់ឃើញថាសមស្រប ដើម្បីគាំទ្រដល់ភាពសុចរិតនៃកិច្ចដំណើរការនីតិវិធីស៊ើបសួរ, និង

ឃ. កំណត់ថា បណ្តឹងសាទុក្ខភ្លាមៗនេះផ្អែកលើមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១១ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY សហព្រះរាជអាជ្ញា | | [signature] |

[85]**D314/1/11** សេចក្តីព្រមានចំពោះការផ្សព្វផ្សាយព័ត៌មានសម្ងាត់ដោយគ្មានការអនុញ្ញាត, ថ្ងៃទី៩ កក្កដា ២០១០, ("សេចក្តីព្រមានចំពោះការផ្សព្វផ្សាយព័ត៌មាន"), កថាខណ្ឌទី ២(គ)-(ង) ។ សេចក្តីណែនាំអនុវត្ត ០០៤/២០០៩៖ ចំណាត់ប្រភេទ និង ការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង, ថ្ងៃទី៥ មិថុនា ២០០៩, មាត្រា ២.ឃ(ii) (ចៅក្រម សហព្រះរាជអាជ្ញា មេធាវីភាគីដើមបណ្តឹង មេធាវីការពារក្តី បុគ្គលិកតុលាការដែលមានសិទ្ធិ និងអ្នកទាំងឡាយណាដែលទទួលបានសិទ្ធិពិនិត្យមើលឯកសារតាមសេចក្តីសម្រេចរបស់ តុលាការជាមុន") ។